STREAM

# របាយការណ៍ស្តីពី

## ការសិក្សាពីនិរន្តរភាពនៃការចិញ្ចឹមជីវិតរបស់កសិករ និង ប្រជានេសាទ

## ភូមិកោះច្បារ

# ឃុំកោះខ្ញែរ ស្រុកសំបូរ ខេត្តក្រចេះ

**ឧបត្ថម្ភដោយ**

**គំរោងគាំទ្រដល់ការគ្រប់គ្រងធនធានវារីជាតិក្នុងតំបន់**

**សហការជាមួយ ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ**

**នៃនាយកដ្ឋានជលផល និង**

**កម្មវិធី ស្កេល**

**សីហា ២០០២**


Bhutan
Bangladesh
Myanmar (Burma)
Laos
Vietnam
Thailand
Cambodia
Paracel Islands
Philippines
Taiwan
Macau
Spratly Islands
Brunei
Malaysia


ខេត្តឧត្តមានជ័យ
ខេត្តព្រះវិហា
ខេត្តបន្ទាយមានជ័យ
ខេត្តសៀមរាប
ខេត្តស្ទឹងត្រែង
ខេត្តរតនះគិរី
ខេត្តបាត់ដំបង
ខេត្តកំពង់ធំ
ខេត្តក្រចេះ
ខេត្តមណ្ឌលគិរី
ខេត្តពោធិសាធ
ខេត្តកំពង់ឆ្នាំង
ខេត្តកំពង់ចាម
ខេត្តកោះកុង
ខេត្តកំពង់ស្ពឺ
ខេត្តព្រៃវែង
ខេត្តកណ្ដាល
ខេត្តស្វាយរាង
ខេត្តកំពត
ខេត្តតាកែវ
N

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំក្រុមសិក្សាស្តីពីការចិញ្ចឹមជីវិតរបស់ប្រជាកសិករ និង អ្នកនេសាទ ដែលបានធ្វើការសិក្សា នៅ ក្នុង ភូមិកោះច្បារ ឃុំកោះខ្ញែរ ស្រុកសំបូរ ខេត្តក្រចេះ ដែលមានសមាសភាពដូចខាងក្រោមៈ-

**<u>សមាសភាពក្រុម</u>** :

- លោក សៀន.គិន
- លោក តាន់. សុមេធប៊ុនវឌ្ឍន៍
- លោកស្រី ជីវ.គីមឆេង
- លោក វិន.ប៊ុណ្ណា
- កញ្ញា ហេ.សុផានណា
- លោក មាស.នីរ៉ែន

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

- គំរោងផ្តួចផ្តើម **STREAM** ដែលជួយឧបត្ថម្ភ ថវិកាសំភារៈក្នុងការសិក្សានេះ ។
- ការិយាល័យអភិវឌ្ឍន៏សហគមន៏ នេសាទ នាយកដ្ឋានជលផល នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ ដែលបានជួយសំរបសំរួលឱ្យក្រុមការងារយើងខ្ញុំធ្វើការសិក្សារហូតដល់ទីបញ្ចប់ ។
- អង្គការ **SCALE** ដែលបានសំរបសំរួលក្នុងការបណ្តុះបណ្តាល និងការចុះសិក្សាផ្ទាល់នៅមូលដ្ឋាន។
- លោក មេភូមិកោះច្បារ ដែលបាន រួមសហការ ជួយលើកទឹកចិត្ត និងសំរប សំរួល ឱ្យមានការចូលរួម ពីអ្នកភូមិក្នុងការសិក្សារហូតបានសំរេចជាស្ថាពរ។
- សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះប្រជាពលរដ្ឋភូមិកោះច្បារ ដែលបានចំណាយពេលវេលាយ៉ាងច្រើនដើម្បីផ្តល់ជាមតិយោបល់យ៉ាងផុសផុល និងពតិមានពីគ្រប់សកម្មភាព និងកត្តា ដែលពាក់ពន្ធ័ ដល់ការចិញ្ចឹមជីវិតរបស់អ្នកភូមិ។ លើសពីនេះទៅទៀតគាត់ហ៊ាននិយាយ ការពិត និងនិយាយត្រង់ជូនដល់ក្រុមសិក្សាដែលធ្វើឱ្យការសិក្សានេះបានទទួលលទ្ធផលល្អ។

# មាតិការ


សង្ខេប និងសន្និដ្ឋាន ១

**១- បរិបទនៃការសិក្សា**

១-១ ទីតាំងភូមិសាស្ត្រ ៣

១-២ ប្រវត្តិភូមិ ៤

**២- លទ្ធផល**

២.១ ការចាត់ថ្នាក់ទ្រព្យសម្បត្តិ ៧

២.២ ធនធានសំខាន់ៗរបស់ភូមិ ១១

២.២.១ ធនធានមនុស្ស ១១

២.២.២ ធនធានហេដ្ឋារចនាសម្ព័ន្ធ ១១

២.២.៣ ធនធានធម្មជាតិ ១២

២.២.៤ ធនធានសង្គម ១៥

២.២.៥ ធនធានហិរញ្ញវត្ថុ ២០

២.៣ ភាពរងគ្រោះ ២៤

២.៤ ស្ថាបន័ និង ដំណើរការ ៣៤

២.៥ យុទ្ធសាស្ត្រចិញ្ចឹមជីវិត ៣៧

២.៦ ការវិភាគដោយយោងទៅតាមគំរោងនិរន្តរភាពនៃការចិញ្ចឹមជីវិត ៤១

**៣- ការសន្និដ្ឋាន** ៤២

**តារាង**


តារាង១: ប្រវត្តិកាល ៤

តារាង២: ចំណាត់ថ្នាក់ទ្រព្យសម្បត្តិ ១០

តារាង៣: ធនធានសំខាន់ៗរបស់ភូមិ ២១

តារាង៤: ការវិភាគលើស្ថាប័ន និងដំណើរការ ៣៤

តារាង៥: ការចាត់ថ្នាក់បញ្ហា ៣៨

តារាង៦: ផែនការកសាងស្ថាន ៤០


**រូបភាព:**


រូបភាពទី១: ទីតាំងស្រុកព្រៃកប្រសព្វ ៦

រូបភាពទី២: ផែនទីកាត់ទទឹង ១៣

រូបភាពទី៣: ផែនទីធនធាន ១៤

រូបភាពទី៤: ផែនទីសង្គម ១៧

រូបភាពទី៥: វេនដ្យាក្រាមបុរស ១៨

រូបភាពទី៦: វេនដ្យាក្រាមស្ត្រី ២០

រូបភាពទី៧: រដូវកាល បុរស ២៥

រូបភាពទី៨: រដូវកាលស្ត្រី ២៧

រូបភាពទី៩: ការប្រែប្រួល ៣២

រូបភាពទី១០: ការវិភាគបញ្ហា ៣៩

រូបភាពទី១១: ទំរង់និរន្តរភាពនៃការចិញ្ចឹមជីវិត ៤១

# ការសង្ខេប និងសន្និដ្ឋានជាដំបូង

ការសិក្សាស្រាវជ្រាវអំពីការចិញ្ចឹមជីវិតរបស់កសិករ និងប្រជានេសាទនេះ គឺផ្អែកទៅលើពត៌មានដែល ផ្តល់ឱ្យដោយអ្នកភូមិ។ ក្រុមការងារបានធ្វើការសំរបសំរួល និងលើកទឹកចិត្តឱ្យអ្នកភូមិចូលរួមផ្តល់នូវគំនិត និង ចំណេះដឹង និង លើក ឡើងនូវបញ្ហាពិត្យៗដែលមានការទាក់ទងទៅនឹងការចិញ្ចឹមជីវិតរបស់គាត់។ បន្ទាប់មក ក្រុមសិក្សាបានធ្វើការកត់ ត្រានូវពត៌មាន និងការរកឃើញនានា ដើម្បីចងក្រងជារបាយការណ៍នេះឡើង។

ការសិក្សានេះបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០២។ ក្រុមសិក្សាបាន ចូលរួម ធ្វើការជាមួយអ្នកភូមិពី ១៥ ទៅ ៣០ នាក់ ពួកគេជាអ្នកស្មគ្រ័ចិត្តចូលរួមដែលជាតំណាងឱ្យអ្នកភូមិ ១៤២ គ្រួសារ នៅក្នុងភូមិនេះ។ ដោយយោងទៅលើភាពខុសគ្នាតនៃសំភារៈ មធ្យោបាយផលិតកម្ម និងក៏រិត ជីវភាពរស់ នៅ ខុសគ្នា អ្នកភូមិបានចែកពួកគេជា ៤ ក្រុមទៅតាមចំណាត់ថ្នាក់ទ្រព្យសម្បត្តិ ហើយក្រុមទាំងនោះមានឈ្មោះថា អ្នកធូធារ អ្នក មធ្យម អ្នកក្រីក្រ និងអ្នកទីទ័លក្រ។ ធនធានសំខាន់ៗ របស់ភូមិត្រូវបានចែកចេញជា ៥ ក្រុម គឺធនធាន មនុស្ស ធនធានធម្មជាតិ ធនធានសង្គម ធនធានហេដ្ឋារចនាសម្ព័ន្ធ និង ធន ធានហិរញ្ញវត្ថុ ។

មានការប្រែប្រួលមួយចំនួនដែលមានផលប៉ះពាល់ដល់ការចិញ្ចឹមជីវិតរបស់អ្នកភូមិ ជាពិសេសការប្រែប្រួលនៃធនធានធម្មជាតិ។ ចំនួនប្រជាជនចេះតែបន្តកើនឡើង ដែលនាំឱ្យការប្រើប្រាស់ធនធានមានការកើនឡើង ហើយទីបំផុត វាធ្វើមានការថយចុះនូវធនធាន។ អ្នកភូមិតែងតែមានការរងគ្រោះដោយសារជំងឺ គ្រុនចាញ់ គ្រុនក្តៅ គ្រុនឈាម។ អ្នក ក្រីក្រខ្វះខាតសំភារៈកសិកម្ម ជាពិសេសកំលាំងអូសទាញ ហើយជា ទូទៅតំលៃផលិតផល របស់អ្នកភូមិទាបជាងនៅទីផ្សារ នៅទីក្រុងដល់ទៅ ៥០%។

បញ្ហាសំខាន់ៗ របស់អ្នកភូមិរួមមាន មធ្យោបាយធ្វើដំណើរនៅទាប ខ្វះទីផ្សារលក់ផលិតផល ទឹកជំនន់ ខ្វះកំលាំងអូសទាញ និងបច្ចេកទេសក្នុងការដាំដុះមានក៏រិត។ លើសពីនេះទៅទៀតទាំងមនុស្ស និងសត្វ ប្រឈមមុខ ទៅនឹងជំងឺ។ ក្រុមសិក្សាបានពិភាក្សា និងសំរបសំរួលអ្នកភូមិក្នុងការចាត់ថ្នាក់បញ្ហា និងវិភាគរកឫសគល់នៃបញ្ហា។ ជាលទ្ធផលគេបានធ្វើផែនការសកម្មភាពមួយដើម្បីការពារជំងឺសត្វ និងបង្កើត ជាធនាគា សត្វ។

ការសន្និដ្ឋានៈ

រឿងរ៉ាវ និងបញ្ហាដែលបានរកឃើញក្នុងកំឡុងពេលសិក្សា នៅក្នុងភូមិកោះច្បារ បានផ្តល់លទ្ធភាពឱ្យក្រុមលើកឡើងនូវការពិចារណាសំរាប់ស្ថានភាពបច្ចុប្បន្ន និងនាពេលអនាគត។ យើងយល់ឃើញថា

អ្នកភូមិបានធ្វើការយ៉ាងល្អជាមួយអ្នកដឹកនាំរបស់គេដែលជាការងាយស្រួលសំរាប់អ្នកខាងក្រៅរួមសហការណ៏ជាមួយ ។ កំណើនប្រជាជនធ្វើឱ្យធនធានធម្មជាតិមានការថយចុះ ។ប្រពន្ធ័គមនាគមន៏មានកំរិតទាបធ្វើឱ្យតំលៃកសិកផល ទាប ។ អ្នកក្រីក្ររង គ្រោះដោយ សារជំងឺ និងខ្វះស្បៀង ។

ក្រុមសិក្សាមានសំណូមពរថា អ្នកភូមិគួតែមានការណែនាំទាក់ទងទៅនឹងបញ្ហាសុខភាពគួរធ្វើការស្រាវលើលទ្ធភាពកសិកម្ម គួរធ្វើការពង្រឹងការគ្រប់គ្រងផលនេសាទនេសាទឱ្យមាននិរន្តភាព និងផ្តល់ឥណទាន ជា សត្វ ចិញ្ចឹម ដើម្បីជួយដល់អ្នកក្រីក្រ ។

មានការលើកឡើងនូវអនុសាសន៏មួយចំនួនពីក្រុមសិក្សា ដែលទាក់ទងទៅនឹងផែនការគ្រួសារ ការបង្កើតសហគមន៏នេសាទ ផែនការសាងសង់ស្ពាន គំរោងឥណទានដែលមានការប្រាក់ទាប និងការបង្កើនចំណេះ ដឹង លើការ ចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ។

# ១_សេចក្តីផ្តើម

## ១-១ ទីតាំងភូមិសាស្រ្ត

ខេត្តក្រចេះ គឺជាខេត្តមួយស្ថិតនៅភូមិភាគឥសាន្តនៃប្រទេសកម្ពុជា ដែលមានចំងាយ ២១៧ គ.ម ពីរាជ ធានីភ្នំពេញ បើធ្វើដំណើរតាមផ្លូវទឹកនៃដងទន្លេមេគង្គលើ និងមានចំងាយ ៣៤១ គ.ម បើធ្វើដំណើរ តាមផ្លូវគោក ផ្លូវជាតិលេខ ៦អា ដោយឆ្លងកាត់ខេត្តកំពង់ចាមហើយបន្តតាមផ្លូវជាតិលេខ ៧ ដោយ ឆ្លងស្ពានគីហ្សុណា។ ដោយផ្លូវជាតិមិនទាន់មានការអភិវឌ្ឍន៏អ្នកដំណើទូទៅនិយមធ្វើដំណើទៅខេត្តក្រចេះ តាមផ្លូវទឹក ដោយ ចំណាយ ពេលប្រ ហែល ៦ម៉ោងតាមកាណូតល្បឿន ។ ខេត្តមានផ្ទៃដី សរុប 11.094Km$^2$ និងមាន ប្រជាពលរដ្ឋចំនួន279.140 នាក់ ត្រូវជា 52.340គ្រួសារ( តាមស្ថិតិជំរឿនជាតិ ឆ្នាំ 1998 ) ។ ក្នុងចំណោម ប្រជាជនទាំងអស់មាន ជនជាតិភាគតិច ចំនួន ៨ក្រុមរស់នៅ គឺ ចាម ព្នង គួយ ស្មៀង មិល គ្រោល ថ្មូន និង ខោញ។ ជនជាតិទាំងនេះច្រើនរស់នៅតំបន់ព្រៃភ្នំដាច់ស្រយាលក្នុង ភូមិសាស្រ្ត ស្រុកសំបូរ ស្រុកក្រចេះ ស្រុកឆ្លូង និងស្រុក ស្នួល។

ខេត្តក្រចេះស្ថិតនៅតំបន់ខ្ពង់រាប ដែលសំបូរទៅដោយព្រៃឈើ សត្វព្រៃ ហើយមានទន្លេមេគង្គ លើ ដែល ជាប្រភពទឹកជាជំរកមច្ឆាជាតិ និងជាពិសេសទៀតទន្លេមេគង្គមានអន្លង់ជ្រៅៗ ដែលជាជំរកត្រី និងសត្វ ផ្សោតដែល ជាប្រភេទសត្វទឹកដ៏កំរ។ សព្វថ្ងៃមានភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ជាច្រើនមកទស្សនា ផ្សោតដែលធ្វើឱ្យគេ ស្គាល់ខេត្តក្រចេះកាន់តែច្រើន។ ដីកសិកម្មភាគច្រើនស្ថិតនៅ តាមដងទន្លេ ព្រែក និង ទំនាបព្រៃលិចទឹក ដែលមាន ទំហំតូចៗត្រូវបានគេកំណត់ជាតំបន់ដីសើម ជាកន្លែងដែលមានសារៈសំខាន់ ដល់ជីវសាស្រ្តចំរុះហើយកន្លែងនេះ ក៏ ជាតំបន់ឡូត៍នេសាទតូចៗផងដែរ ។ បច្ចុប្បន្នឡូនេសាទទាំងអស់របស់ ខេត្តក្រចេះត្រូវបានប្រគល់ ឱ្យសហគមន៏ ជាអ្នកគ្រប់គ្រង ។

ខេត្តក្រចេះមានចំនួនប្រាំស្រុកគឺ ស្រុកសំបូរ ស្រុកក្រចេះ ស្រុកព្រែកប្រសព្វ ស្រុកឆ្លូង និងស្រុកស្នួល ហើយមានព្រំប្រទល់ខាងជើងជាប់នឹងខេត្តស្ទឹងត្រែង និងខេត្តមណ្ឌលគីរី ខាងលិចជាប់ នឹងខេត្តកំពង់ធំ ខាងត្បូង ជាប់នឹងខេត្តកំពង់ចាម ខាងកើតជាប់នឹងប្រទេសវៀតណាម។ ក្រុមសិក្សា បានជ្រើសរើសភូមិកោះច្បារ ដែលស្ថិតនៅក្នុងឃុំកោះខ្នែរ ស្រុកសំបូរដើម្បីធ្វើការសិក្សា ដោយចំណាយ ពេល៦ថ្ងៃ នៅក្នុងភូមិជាមួយអ្នកភូមិ។ ភូមិកោះច្បារ ស្ថិតនៅតាមដងទន្លេមេគង្គជាប់នឹងឡូត៍នេសាទ ដែលបានរំសាយ គឺព្រែកអូរតាណឹង អតីត ឡូត៍លេខ ២ របស់ខេត្ត ដែលជាតំបន់ខ្ពង់រាបព្រៃស្រោងរបោះ។ ភូមិមានបណ្តោយ 12km ទទឹង4km មាន ផ្ទៃដី 4.800ha និង មានព្រំ ប្រទល់ខាងកើត ទល់នឹងព្រៃទ្រាល (ឃុំក្បាល ដំរី) ខាងលិចទល់នឹងទន្លេ មេគង្គខាងត្បូងទល់នឹង អូរតាណឹង ខាងជើងទល់នឹងអូរស្វាន។ ប្រជាពលរដ្ឋក្នុងភូមិ មាន ៦៧២ នាក់ ត្រូវជា ១៤២គ្រួសារ ក្នុងចំនួននេះ

មានព្នង ប្រមាណជា 4,2 %គួយប្រមាណជា1,4% នៃប្រជាជនសរុប។ ពួកគាត់ភាគច្រើនប្រកបរបរធ្វើស្រែ និង រុក រកផល-អនុផលព្រៃឈើ ដើម្បីចិញ្ចឹមជីវិត ។

## ១-២ ប្រវត្តិភូមិកោះច្បារ

កាលពីសម័យដើមឡើយភូមិកោះច្បារគឺ ជាកោះមួយតូច មានមនុស្សរស់នៅតែ ៥ គ្រួសារប៉ុណ្ណោះ។ ពួកគេប្រកបរបរដាំដំណាំនៅលើកោះនេះ ដែលជាហេតុធ្វើឱ្យអ្នកស្រុកជិតខាងហៅថាកោះអ្នកធ្វើច្បារដំណាំ។ លុះក្រោយមកដោយសារប្រជាជនចូលចិត្តហៅតែត្រឹមកោះច្បារ ដូចនេះ ឈ្មោះភូមិកោះអ្នកធ្វើច្បារដំណាំ បាន ក្លាយមកជាឈ្មោះ ភូមិកោះច្បារវិញ។

ក្នុងសម័យអាណានិគមនិយមបារាំង មានព្រឹត្តិការណ៍មួយផ្ទុះឡើងគឺការបះបោរឡើងរបស់ក្រុមព្នង និង ពួកអ្នកទោសនៅខេត្តស្ទឹងត្រែងដែលបានទំលាយគុក រួមដៃជាមួយព្នងប្រឆាំងនឹងបារាំង។ ក្រុមអ្នកភូមិ កំពុងកុយ អូរគ្រៀង ប្រមាណ ៥គ្រួសារមានអសន្តិសុខក៏ភាសខ្លួនមកនៅលើកោះច្បារនេះ។ ដោយទំហំកោះ តូច ហើយកំណើនមនុស្សចេះតែច្រើនអ្នកភូមិក៏ប្តូរទីលំនៅមករស់នៅភូមិជាប់ច្រាំងម្ខាងដែលជាភូមិសព្វថ្ងៃ នេះ តែគេនៅហៅថាកោះច្បារដដែលរហូតមក។

តារាងទី១:

ព្រឹត្តិការណ៍ដែលកើតមានឡើងនៅតាមសម័យកាលនីមួយៗត្រូវបានពិពណ៌នាក្នុងតារាងខាងក្រោម :

| | |
|---|---|
| សម័យមុនឥស្សរៈ<br>ឆ្នាំ១៩៤០-១៩៤៥ | ភូមិស្ថិតនៅលើកោះតូចមួយ ដែលមានប្រជាជនរស់នៅប្រមាណ៥គ្រួសារ។ អ្នកភូមិលើកោះបានដាំដំណាំកសិកម្ម ធ្វើឱ្យអ្នកស្រុកជិតខាង និងអ្នកភូមិហៅភូមិនេះថាកោះអ្នកធ្វើច្បារដំណាំ។ ក្រោយមកពាក្យកោះច្បារដំណាំនោះ ក៏ក្លាយទៅពាក្យ ថា កោះច្បារ ។ |
| សម័យឥស្សរៈ<br>ឆ្នាំ១៩៤៦-១៩៥៣ | មានព្រឹត្តិការណ៍បះបោររបស់អ្នកទោសនៅខេត្តស្ទឹងត្រែងបានបុកទំលាយគុក ហើយក្រុមជនជាតិព្នងក៏បះបោររួមគ្នាប្រឆាំងនឹងបារាំង។ អ្នកភូមិកំពុងកុយ ៥ បានភាសខ្លួនមករស់នៅលើកោះជាមួយអ្នកស្រុកកោះច្បារ។ |
| ឆ្នាំ១៩៥៣-១៩៦០ | នៅសម័យនោះប្រជាពលរដ្ឋភូមិកោះច្បារមានការខ្វះខាតស្បៀង និង សំលៀក បំពាក់យ៉ាងខ្លាំងហើយពួកគាត់បានយកបាវធ្វើជាសំលៀកបំពាក់ទាំងប្រុស ទាំង ស្រី ចំណែកនៅផ្ទះវិញពួកគាត់រុំកន្ទប ។ គេប្រើបំពង់ប៉ុយ សំរាប់បង្កាត់ភ្លើង ហើយ នៅសម័យនោះមានជំងឺអាសន្នរោគយាយីដល់អ្នកភូមិ ។ ក្រោយមកដោយកំណើន ប្រជជនកើនរហូតដល់ ៣៨គ្រួសារ អ្នកភូមិក៏ មករស់នៅឯ នាយច្រាំងម្ខាងវិញ។ |
| ឆ្នាំ ១៩៦២ | ប្រជាជនកើនដល់៧២គ្រួសារ ប្រកបរបរធ្វើស្រែចំការ រុករកផល អនុផលព្រៃឈើ និង |

| | |
|---|---|
| | នេសាទត្រីជាច្រើន ។ ជំនាន់នោះមានជំងឺមួយកើតឡើងរាតត្បាត យាយីដល់ អ្នកភូមិ គឺជំងឺអុត។ រឿងមួយទៀតនៅសម័យនោះមានត្រីពពែស(ពោព្រុយ) បាន ខាំមនុស្ស នៅអន្លង់កោះច្បារ ។ ប្រពៃណីរបស់អ្នកស្រុកស្រីៗបួងសក់ បុរសកាត់ សក់ខ្លី ការតុប តែងលំអរបស់ស្រ្តីដោយប្រើគ្រឿងអលង្ក៏កាអង្កាំ។ |
| ឆ្នាំ១៩៧០-១៩៧៥ | សម័យរដ្ឋប្រហារទំលាក់គ្រាប់បែកពីសំណាក់ពួកលន់ណុល អ្នកស្រុកភ័យខ្លាច។ ការធ្វើស្រែចំការ នេសាទត្រី និង រកស៊ីមិនបានរវល់រត់គេចពីគ្រាប់បែក។ ដែល ជាផលពិបាកធ្វើអោយមានការខ្វះខាតស្បៀងជាអន្លើៗ ។ នៅឆ្នាំ ១៩៧៥ ចំនួន ប្រជាជនក្នុងភូមិកោះច្បារបានកើនឡើងដោយសារ ពួកប៉ុលពតបានបញ្ជូន ប្រជា ជន ដែលរស់នៅទីក្រុង អោយមករស់នៅក្នុងភូមិនេះ ។ |
| ឆ្នាំ១៩៧៥-១៩៧៩ | សម័យប៉ុលពត ពួកអង្គការបានបង្កើតឡើងនូវសហករណ៍ ហូបបាយរួមធ្វើ ស្រែចំការ នេសាទជាក្រុមសាមគ្គី ឬ សហករណ៍។ ការរស់នៅបែងចែកតាម វ័យរបស់មនុស្ស។ ប៉ុលពតជំលៀសអ្នកភូមិចេញពីភូមិ តែពួកគាត់គេចពួន តាម កោះកាំង ក្នុងស្រុក សំបូរ ។ មកដល់ឆ្នាំ១៩៧៩វៀតណាមចូលមកដល់តំបន់ស្រែ ស្បូវ ពួកអ្នកភូមិក៏រត់ ទៅឱ្យទ័ពរំដោះជាតិខ្មែរជួយ ហើយទ័ពវៀតណាមក៏ ជូន អ្នកភូមិ ត្រលប់មកកោះ ច្បារវិញ ដែលនៅពេលនោះមានតែប្រជាជនចំនួន ៣០គ្រួសារ ប៉ុណ្ណោះ ។ |
| ឆ្នាំ១៩៧៩-១៩៨៤ | ប្រជាជនចំនួន ៨០គ្រួសារ ធ្វើការជាក្រុមសាមគ្គី ពេលនោះមានទឹកជំនន់លិចភូមិ។ ការនេសាទត្រីងាយស្រួល ដោយសារសំបូរត្រី សត្វ ព្រៃឈើ ។ |
| ឆ្នាំ១៩៨៥-១៩៩០ | ប្រជាជនមានចំនួន ៩០គ្រួសារ ពេលនោះរដ្ឋាភិបាលបានចាប់ផ្តើមកំណែទំរង់ ដីធ្លី ដោយបែងចែកដីធ្លីតាមគ្រួសារនីមួយៗពោលគឺតាមកេ្តិ៍អាករឡើងវិញ។ អ្នកស្រុក គោ រពព្រះពុទ្ធសាសនា ។ |
| ឆ្នាំ១៩៩១-២០០២ | បច្ចុប្បន្ននេះប្រជាជនមានចំនួន១៤២គ្រួសារ ដែលក្នុងនោះពួកគាត់ប្រកបរបរធ្វើ ស្រែ ចំការ នេសាទ រុករកផល-អនុផលព្រៃឈើ និងមានសិទ្ធិសេរីភាពក្នុងការបញ្ចេញ មតិយោបល់បោះ ឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន គិតចាប់តាំង ពីការប ង្កើត សហគមន៍ជង្រុកស្រូវ គណៈកម្មការអភិវឌ្ឍន៍ភូមិ សហគមន៍នេសាទ ជាដើម។ល។ |


N
ស្រុកសំបូរ
ស្រុកក្រចេះ
ស្រុកព្រែកប្រសព្វ
ស្រុកឆ្លូង
ស្រុកស្នួល

# ២_លទ្ធផល

លទ្ធផលនៃការសិក្សានេះគឺរៀបចំឡើងដោយយោងទៅតាមគំរោងនិរន្តរភាពការចិញ្ចឹមជីវិត ដែលមានធនធាន ភាពរងគ្រោះ ដំណើរការ និងយុទ្ធសាស្ត្រនៃការចិញ្ចឹមជីវិត ។

## ២-១ ចំណាត់ថ្នាក់ទ្រព្យសម្បត្តិ

ក្នុងការចាត់ថ្នាក់ទ្រព្យសម្បត្តិនេះក្រុមសិក្សាបានអញ្ជើញមនុស្សចាស់ៗ និងគណកម្មការភូមិមកចូលរួមធ្វើការវិនិច្ឆ័យដោយយោងទៅតាមធនធាន និងស្ថានភាពគ្រួសារនិមួយៗ ពួកគាត់បានសំរេចបែងចែកអ្នកភូមិជាបួនក្រុម :

១- ក្រុមអ្នកធូរធារ : មាន ២៩គ្រួសារ ស្មើ នឹង ២០ %

២- ក្រុមអ្នកមធ្យម : មាន ៥២គ្រួសារ ស្មើ នឹង ៣៧ %

៣- ក្រុមអ្នកក្រីក្រ : មាន ២៤គ្រួសារ ស្មើ នឹង ១៧ %

៤- ក្រុមអ្នកទីទ័លក្រ : មាន ៣៧គ្រួសារ ស្មើ នឹង ២៦ %

*ក្រុមទី១ ក្រុមអ្នកធូរធារ :*

ក្រុមនេះមាន ២៩គ្រួសារ ស្មើនឹង ២០ %នៃចំនួនគ្រួសារសរុបក្នុងភូមិ ពួកគេមានដីបង្កបង្កើនផលពី ២,៥-២,៨ហិកតា ហើយមានលទ្ធភាពរុករានដីថ្មីបន្តទៀត។ គេអាចផលិតស្រូវបានពី ១៥០-៣០០ថាំង/ឆ្នាំ ស្មើនឹង ៣.៦០០ –៧.២០០គ.ក្រ។ ផលស្រូវនេះហូបគ្រប់គ្រាន់ពេញមួយឆ្នាំ និងអាចបណ្តាក់ឱ្យអ្នកក្រីក្រក្នុង ភូមិទៀតផង។ ពួកគេភាគច្រើនមានសំភារៈកសិកម្ម និងកំលាំងអូសទាញគ្រប់គ្រាន់ ភាគច្រើនមានក្របីពី ២-៥ ក្បាល គោ ៣-១០ក្បាល។ ចំណែកមធ្យោបាយធ្វើ ដំណើរមានដូចជា ទូក កាណូត រទេះគោ និងមានសំភារៈប្រើប្រាស់មួយចំនួនទៀតដូចជា វីដេអូ ទូរទស្សន៍ ម៉ាញេ វិទ្យុ។ ក្រុមនេះមាន ១០គ្រួសារ ដែលមានកាណូត ប្រើប្រាស់ ។

ក្រៅពីការដាំដុះគេមានមុខរបរផ្សេងៗទៀតដូចជា នេសាទត្រី កាប់ឬស្សី បោចវល្លិ ផ្តៅ កាប់សរសរ បិតស្រា និងកិនស្រូវជាដើម ។

*ក្រុមទី២ ក្រុមអ្នកមធ្យម :*

ក្រុមមធ្យមមានចំនួន ៥២គ្រួសារ ស្មើនឹង ៣៧ %នៃចំនួនគ្រួសារសរុបក្នុងភូមិដែលមានផ្ទៃដីស្រែចំការជាមធ្យម០,៦-១ហិចតាដែលទទួលផលស្រូវពី៥០-១០០ថាំងស្មើនឹង១.២០០-២.៤០០គ.ក្រ ក្នុងឆ្នាំ។ ផលស្រូវរបស់គាត់ប្រែប្រួលអាស្រ័យទៅលើកត្តាធម្មជាតិ ជាពិសេសទឹកជំនន់ និងទីតាំងដីស្រែរបស់ពួកគាត់។ ពួកគាត់មានសំភារៈកសិកម្ម និងកំលាំងអូសទាញគ្រប់គ្រាន់ ៧០%

នៃក្រុមនេះមានគោក្របីសំរាប់ប្រើប្រាស់ជា កំលាំងអូសទាញ។ មធ្យោបាយធ្វើដំណើរមានទូក កាណូត រទេះគោ ក្នុងនោះមាន ១៧ គ្រួសារមានកាណូតប្រើ ប្រាស់ ក្រៅពីនេះគេមានសំភារៈផ្សេងៗទៀត ដូចជា ទូរទស្សន៍ ម៉ាញេ វិទ្យុ និង មាស៊ីនបូមទឹក ។

ក្រៅពីចំណូលបានមកពីផលស្រូវពួកគាត់មានមុខរបរបន្ថែមទៀតនៅរដូវប្រាំង ដូចជា កាប់ឬស្សី បោច វល្លិ៍ ដងជ័រ និងកាប់សរស។ ចំណែកឯការការចិញ្ចឹមសត្វវិញគ្រួសារខ្លះមានគោ ក្របី ផ្ទាល់ខ្លួនជាមធ្យម ពី ២-៥ ក្បាល។

*ក្រុមទី៣ក្រុមអ្នកក្រីក្រ :*

ក្រុមនេះមាន ២៤គ្រួសារ ស្មើ នឹង ១៧ % នៃគ្រួសារក្នុងភូមិ ពួកគាត់ភាគច្រើន មានដីបង្កបង្កើនផលតិចតួច ដែលជាមធ្យមពី ០,៥-០,៧៥ហិកតា ផលស្រូវដែលផលិតបាន អាចហូបក្នុង រយៈពេលពាក់កណ្តាលឆ្នាំ ប៉ុណ្ណោះ។ នៅពេលដែលខ្វះខាតពួកគាត់ខ្ចីបុល និងស៊ីឈ្នួលអ្នកធូរធារដូចជា កាប់ឬស្សី ចាំងសរសរ ជាដើម ជាងពាក់កណ្តាលនៃគ្រួសារនៅក្រុមនេះមិនមានគោ ឬរទេះដើម្បីទៅ កាប់ឬស្សី ឬកាប់សរសរដោយខ្លួនឯងទេ ខ្លះមានគោដែរតែជាគោញីមិនអាចប្រើប្រាស់បាន។ គេមាន សំភារៈ ប្រើប្រាស់តិចតួចដូចជា វិទ្យុ ទូក មានតែ មួយគ្រួសារទេដែលមាកាណូតប្រើ។

*ក្រុមទី៤ ក្រុមអ្នកទីទ័លក្រ :*

ក្រុមនេះមានចំនួន ៣៧គ្រួសារ ស្មើនឹង ២៦ % នៃគ្រួសារក្នុងភូមិ ពួកគេមានដីស្រែច្រើនបំផុត ០,៥ ហិកតា ក្នុងមួយគ្រួសារ ដែលអាចផលិតស្រូវបានច្រើនបំផុត ២០ថាំងស្មើនឹង ៤៨០គ.ក្រ។ ផលស្រូវនេះអាច បំរើឱ្យការហូបចុកតែ ៣-៤ខែប៉ុណ្ណោះ ដូចនេះត្រូវខ្វះខាតរយៈពេលវែងក្នុងមួយឆ្នាំៗ។ ក្នុងចន្លោះពេលខ្វះខាត ពួកគាត់ពឹងផ្អែកទៅលើការស៊ីឈ្នួលធ្វើការងារនៅក្នុងភូមិដូចជា ដកស្ទូង កាប់ឬស្សី បោចវល្លិ៍ ចាំងសរសរ ប្រមាញ់សត្វព្រៃ និងរុករកផលអនុផលព្រៃឈើផ្សេងៗទៀត។ ចំពោះមធ្យោបាយ ធ្វើដំណើរ សំភារៈកសិកម្ម និងការចិញ្ចឹមសត្វ នៃក្រុមនេះមានតិចតួច ឬ គ្មានតែម្តង។

ភូមិកោះច្បារជាភូមិមួយនៅឆ្ងាយដាច់ស្រយាលដែលពិបាកក្នុងការធ្វើដំណើរដូចនេះការព្យាបាល ជំងឺ ជាទូទៅប្រជាពលរដ្ឋភាគច្រើនប្រើថ្នាំបុរាណដែលផ្សំនៅក្នុងភូមិ។ ដោយឡែកថ្នាំពេទ្យលក់ក្នុងភូមិ មានបន្តិច បន្តួចដែលគ្មានការត្រួតពិនិត្យឱ្យបានត្រឹមត្រូវ។ នៅក្នុងភូមិមានសាលារៀន ក៏ប៉ុន្តែអាចធានា ឱ្យសិស្សរៀន បានត្រឹមតែថ្នាក់ទី៣ប៉ុណ្ណោះ។ អ្នកភូមិគ្មានលទ្ធភាពបញ្ជូនកូនឱ្យទៅរៀនបានច្រើនទេ គេអាចរៀនបានជ្រៅ ជ្រះដោយបួសជាសង្ឃរៀនតាមវត្តដែលនៅឆ្ងាយពីភូមិ បច្ចុប្បន្នមានអ្នកភូមិបួស ជាសង្ឃ ១៦អង្គ។ អង្គការ OCAAបានធ្វើកម្មវិធី ធនាគារស្រូវសំរាប់ជួយដល់អ្នកភូមិ ជាផ្នែកមួយជួយ ដោះស្រាយជីវភាពរបស់ប្រជាជនក្នុងភូមិ។ អ្នកភូមិកោះច្បារភាគច្រើនមានមុខរបរបន្ថែមដូចជា កាប់

ឬស្សី ចាំងសរសរ រកវល្លិ រកជ័រ ប៉ុន្តែមាន លក្ខណៈខុសគ្នាត្រង់ ក្រុមទី១ និង ក្រុមទី២ ជាអ្នកជួលកំលាំងពលកម្ម រីឯ ក្រុមទី៣ និង ក្រុមទី៤ ជាអ្នកស៊ី ឈ្នួលធ្វើការងារដូចខាងលើនេះ។

*តារាងទី២:* **ចំណាត់ថ្នាក់ទ្រព្យសម្បត្តិ**

| ប្រភេទ | អ្នកធូរធារ ២០% | អ្នកមធ្យម ៣៥ % | អ្នកក្រីក្រ ១៥ % | អ្នកទីទ័លក្រ ២៧ % |
|---|---|---|---|---|
| ដីស្រែ វស្សា | ១.៥- ២.៨ ហិកតា | ០.៦- ១ ហិកតា | ០.៤ - ០.៧ ហិកតា | ០- ០.៥ ហិកតា |
| ទិន្នផលស្រូវ | ១៥០- ៣០០ថាំង<br>(៣.៦០០-៧២០០គក្រ) | ៥០-១០០ថាំង<br>(១២០០-២.៤០០គក្រ) | ៣០-៥០ថាំង<br>(៧២០-១.២០០គ.ក្រ) | ០- ២០ថាំង<br>(៤៨០គ.ក្រ) |
| សុវត្ថិភាពស្បៀង | ហូបគ្រប់គ្រាន់១ឆ្នាំ និងសល់លក់ | គ្រួសារភាគច្រើនមានស្បៀង | ខ្វះខាតស្បៀងពាក់កណ្តាលឆ្នាំ | មានហូបតែក្នុងពេលប្រមូលផល |
| មធ្យោបាយធ្វើដំណើរ | រទេះគោ ទូក ទូកម៉ាស៊ីន ( ១៣សេះ ) | រទេះគោ ទូក ទូកម៉ាស៊ីន | ទូក រទេះគោ | ទូកតូចៗ |
| សំភារៈប្រើប្រាស់ | ទូរទស្សន៍ ម៉ាញេ ម៉ាស៊ីនបូមទឹក វិទ្យុ | ទូរទស្សន៍ ម៉ាញេ វិទ្យុ | វិទ្យុ | គ្មាន |
| សំភារៈកសិកម្ម | រទេះ រនាស់ នង្គ័ល | រនាស់ នង្គ័ល | រនាស់ នង្គ័ល | រនាស់ នង្គ័ល |
| ឧបករណ៍នេសាទ | លបង២ សំណាញ់ មងច្រើន | មង សំណាញ់ លបង២-៥ | មង លប សំណាញ់ | លបង២ សំណាញ់ |
| ឥណទាន | អោយគេខ្ចីបុល | | ខ្ចីបុលគេ | ជំពាក់គេ |
| ការចិញ្ចឹមសត្វ | -ជ្រូកពី៣- ៤ក្បាល<br>-គោ ៣-១០ក្បាល<br>-ក្របី ២-៥ក្បាល | -ជ្រូកពី១-២ក្បាល<br>-គោ ២-៥ក្បាល<br>-ក្របី២-៥ក្បាល | -ជ្រូក ១ក្បាល<br>-គោ ១ក្បាល<br>-ក្របី១ក្បាល | -ជ្រូក១ក្បាល |
| មុខរបរបន្ថែម | -ធ្វើស្រែ នេសាទត្រី កាប់ឬស្សី<br>កាប់សរសរ លក់ដូរ បោចវល្លិ៍ ផ្តៅ | -នេសាទត្រីតិចតួច<br>- បិតស្រា បោចវល្លិ ផ្តៅ | ស៊ីឈ្នួលគេ នេសាទត្រី<br>តិចតួច | ស៊ីឈ្នួលគេក្នុងភូមិនិង<br>ក្រៅភូមិ បោចវល្លិ៍ផ្តៅ |
| ការរៀនសូត្រ | ថ្នាក់ទី ៣ | ថ្នាក់ទី ៣ | ថ្នាក់ទី ៣ | ថ្នាក់ទី ៣ |
| ទូកម៉ាស៊ីន | ទូកម៉ាស៊ីន ១០គ្រឿង | ទូកម៉ាស៊ីន ១៤ គ្រឿង | ទូកម៉ាស៊ីន ១ គ្រឿង | ទូកម៉ាស៊ីន ១ គ្រឿង |
| ការព្យាបាលជំងឺ | - ចាក់ថ្នាំពេទ្យឯកជនក្នុងភូមិ | - ចាក់ថ្នាំពេទ្យឯកជនក្នុងភូមិ | ថ្នាំបុរាណ | ថ្នាំបុរាណ |

## ធនធានសំខាន់ៗរបស់ភូមិ

**២.២.១ ធនធានមនុស្ស**

ជាទូទៅអ្នកភូមិមានជំនាញក្នុងការធ្វើកសិកម្មដូចជាធ្វើស្រែវស្សា ស្រែបណ្តែញទឹក ធ្វើចំការ នេសាទត្រី ការរុករកអនុផលព្រៃឈើ ប្រមាញ់ និងធ្វើសិប្បកម្មតុ កៅអី ទ្វាបង្អួចជាដើម។ ជំនាញទាំងនេះមានតាំងពីយូរយារណាស់មកហើយដែលអ្នកភូមិចេះតៗគ្នាពីបុព្វបុរសរបស់ពួកគាត់។ នៅក្នុងភូមិមានអ្នកដឹកនាំសំខាន់ៗ ដូចជាមេភូមិ អាចារ្យក្នុងភូមិ គណៈកម្មការអភិវឌ្ឍន៍ភូមិ ពេទ្យឯកជន ដែលជាអ្នកអាចចូលរួមជួយដោះ ស្រាយរាល់បញ្ហាដែលកើតមាននៅក្នុងភូមិ និងចូលរួមដឹកនាំការងារអភិវឌ្ឍន៍ដូចជាការបង្កើតឥណទានស្រូវ ព្យាបាលសត្វ និងការទប់ស្កាត់បទល្មើសនេសាទដែល កើតមាននៅក្នុងភូមិរបស់គាត់ថែមទៀតផង។

ធនធានមនុស្សនៅក្នុងភូមិនេះមាន មេភូមិ គ្រូបង្រៀន ជាងផ្ទះ គ្រូខ្មែរ ឆ្មបបុរាណ គ្រូថ្នាំបុរាណ អ្នក បិតស្រា ពេទ្យភូមិ អ្នកស្ម័គ្រចិត្តកាកបាទក្រហម គណៈកម្មការនេសាទ គណៈកម្មការពេទ្យសត្វភូមិ គណៈកម្មការជង្រុកស្រូវ គណៈកម្មការម៉ាស៊ីនបូមទឹក អ្នកឡើងត្នោត និងអ្នកលក់ដូរ។ ពួកគេទាំងនេះជាអ្នកដែល មានសកម្មភាពទ្រទ្រង់ដលជីវភាពគ្រួសាររបស់ពួកគាត់ ហើយជាអ្នករស់នៅក្នុងភូមិនេះ។

ជាទូទៅអ្នកភូមិអាចអាន និងសរសេរបានបន្តិចបន្តួចតែប៉ុណ្ណោះ ហើយចំពោះក្មេងៗវិញមានលទ្ធភាព រៀនបានត្រឹមថ្នាក់ទី៣ប៉ុណ្ណោះ ព្រោះនៅភូមិមានត្រឹមតែថ្នាក់បឋមសិក្សា។

**២.២.២ ធនធានហេដ្ឋារចនាសម្ព័ន្ធ :**

ភូមិកោះច្បារជាភូមិដែលនៅឆ្ងាយដាច់ស្រយាល ជាទូទៅអ្នកភូមិជួបការលំបាកក្នុងការធ្វើដំណើរទៅកាន់ទីប្រជុំជន។ នៅក្នុងភូមិនេះមានតែផ្លូវលំ ដែលតភ្ជាប់ពីពាមអូរតាហ៊ើង រហូតដល់អូរស្វាន ដែលមានប្រវែង ៤ គីឡូម៉ែត្រ ផ្លូវនេះស្ថិតនៅតាមបណ្តោយមាត់ទន្លេមេគង្គ។ ផ្លូវលំនេះអាចធ្វើចរាចរបានតែរទេះគោ និង ថ្មើរ ជើងតែប៉ុណ្ណោះ នៅរដូវវស្សាពោរពេញទៅដោយភក់ជ្រាំពិបាកក្នុងការធ្វើចរាចរទៅមកណាស់ គេអាចធ្វើដំ ណើរដោយជើង សូម្បីតែកង់ក៏មិនអាចប្រើបានដែរ ដូចនេះហើយនៅក្នុងភូមិទាំងមូលមិនមានកង់ទេ។ ដើម្បី ធ្វើដំណើរមកទីរួមស្រុកសំបូរពួកគាត់ត្រូវធ្វើ ដំណើរតាមទូកផ្ទាល់ខ្លួន ឬ ពឹងពាក់អ្នកជិតខាងដែលមានទូក។

អ្នកភូមិបានលើកទំនប់តូចៗចំនួន ៣កន្លែងសំរាប់បំរើការស្រោចស្រព ទំនប់នោះគឺទំនប់ស្រែវែង ទំនប់ខ្មុ្ព និងទំនប់ស្រែក្រសាំង ហើយមានម៉ាស៊ីនបូមទឹកចំនួន ៣គ្រឿង ១គ្រឿងបានមកពីការឧបត្ថម្ភរបស់អង្គការ OCAA សំរាប់ធ្វើស្រែបណ្តែញទឹក និងស្រែវស្សានៅពេលជួបគ្រោះរាំងស្ងួតម្តងម្កាល។

ក្រៅពី នេះ ក្នុងភូមិមានវិទ្យុទាក់ទង ១គ្រឿង ម៉ាស៊ីនកិនស្រូវ ៥ តូបលក់ចាប់ហួយ ៥ កន្លែង សាលាឆទាន ១ខ្នង។

វិស័យអប់រំនៅក្នុងភូមិកោះច្បារមានសាលារៀន ១ខ្នង មាន ២បន្ទប់ដែលមានសិស្សចូលរៀនចំនួន ១២៣នាក់ ។

**២.២.៣ ធនធានធម្មជាតិ :**

ធនធានធម្មជាតិមានតួនាទីយ៉ាងសំខាន់ក្នុងការចិញ្ចឹមជីវិតរបស់អ្នកភូមិ ។ ធនធានទាំងនេះមាន ទន្លេ ព្រែក អូរ ដីកសិកម្ម ដីភូមិ ព្រៃឈើ និងដីព្រៃដែលអាចរុករានធ្វើស្រែចំការបាន។ ទន្លេ ព្រែក អូរ ជាប្រភពផ្ត ល់ ត្រី និងធនធានវារីជាតិផ្សេងៗ ។ ក្រៅពីនេះទន្លេ និងព្រែកក៏ជាប្រភពនាំដីដែលមាន ជីជាតិសំរាប់ស្រោចស្រពលើដីស្រែចំការរបស់ពួកគាត់ផងដែរ។ នៅតាមមាត់ព្រែកសំបូរទៅដោយព្រៃលិចទឹក ដែលបង្កលក្ខណៈងាយស្រួលដល់ការរស់នៅនិងពងកូនរបស់ពពួកមច្ឆាជាតិនៅរដូវទឹកឡើងចន្លោះ ខែមិថុនា រហូតដល់ខែសីហា ។

ភូមិមានបណ្តោយ ១២គមទទឹង ៤គម មានផ្ទៃដី ៤៨០០ហិកតា។ ផ្ទៃដីកសិកម្មសរុបរបស់ភូមិមាន ២២៩ហិកតា ក្នុងនោះផ្ទៃដីស្រែវស្សាមាន ១៣៩ហិកតា និង ដីស្រែ បណ្តេញទឹកមាន ៩០ហិកតា ដីដែលនៅ សេសសល់ជាដីព្រៃ (តាមការសាកសួរពត៌មានពីអ្នកភូមិ )។ ក្រៅពីនេះអ្នកភូមិកំពុងរុករានដីព្រៃ និង ព្រៃ លិចទឹកដើម្បីធ្វើដីស្រែ ចំការ ដែលមានចំងាយពីភូមិប្រហែល ៧គ.ម- ១០គ.ម ដោយមានជនជាតិ ខ្មែរ ព្នង និង គួយរស់នៅទីនោះ។ ចំពោះព្រៃឈើដែលស្ថិតនៅឆ្ងាយពីភូមិប្រហែល ៧គ.ម- ១០គ.ម គឺជាប្រភព ផ្តល់ អុស ឈើសំណង់ វល្លិផ្តៅ ជ័រ ស្បូវ រុក្ខជាតិឱសថបុរាណ និង សត្វព្រៃ បក្សីជាច្រើន ប្រភេទជាពិសេស ជ្រូក ព្រៃដែលកពុងមានការកើនឡើង។

ធនធានធម្មជាតិរបស់ភូមិនេះមានការថយចុះជាបន្តបន្ទាប់ដោយសារភាពអណាធិបតេយ្យជាពិសេស ព្រៃឈើ សត្វព្រៃ និងធនធានមច្ឆាជាតិ។ បច្ចុប្បន្ននេះរដ្ឋាភិបាលកំពុងមានវិធានការទប់ស្កាត់ការកាប់បំផ្លាញ ព្រៃឈើការទាញយកផលផ្សេងៗពីព្រៃឈើ និងមានការកែទំរង់លើការគ្រប់គ្រង់ក្នុងវិស័យជលផលដោយមានកិច្ចសហការជាមួយអង្គការ OCAA និងការិយាល័យនេសាទខេត្ត បង្កើតសហគមន៍នេសាទដើម្បីការពារធនធានទាំងនេះអោយមាននិរន្តរភាពឡើងវិញ។

**ចំនុះកាត់ទទឹងភូមិ[illegible]**



| សណ្ឋានដី | ទន្លេ | ដីភូមិ | ដីការពិចស្រែវស្សា | ព្រៃរបោះ | ស្រែវស្សា | ព្រៃរបោះ | ស្រែវស្សាតក់ទ្រូង | ព្រៃរបោះ-ស្រោង | ស្រែត្នោត | ព្រៃរបោះ-ស្រោង |
|---|---|---|---|---|---|---|---|---|---|---|
| ប្រភេទដី | ដីឡាច់, កណ្តួច, ធ្នូ | ដីល្បាយខ្សាច់ | ល្បាយខ្សាច់, ដីកណ្តួច | ល្បាយខ្សាច់, ថ្មូ កណ្តួច, ក្រួស | ល្បាយខ្សាច់, ដីកណ្តួច | ល្បាយខ្សាច់, ថ្មូ កណ្តួច, ក្រួស | ល្បាយខ្សាច់, ដីកណ្តួច | ល្បាយខ្សាច់, ថ្មូ កណ្តួច, ក្រួស | ដីកណ្តួចខ្មៅ | ល្បាយខ្សាច់, ថ្មូ កណ្តួច, ក្រួស |
| ដំណាំ | | ដំណាំភូមិ-ស្រុក | ស្រែវស្សា, ស្រូវពី ដំណាំ, បន្លែ | បន្លែបង្កា យថាផល | ស្រូវវស្សា | បន្លែបង្កា យថាផល | ស្រូវវស្សា | បន្លែបង្កា យថាផល | ស្រូវវស្សា | ព្រៃឈើ |
| ប្រភេទរុក្ខជាតិ | ប្រភេទព្រៃលិចទឹក | ដំណាំភូមិ-ស្រុក | ពោត, ស្រូវ, ត្រប់ ត្រសក់, ត្រឡាច | ព្រៃឈើ | ស្រូវវស្សា | ព្រៃឈើ | ស្រូវវស្សា | ព្រៃឈើ | ស្រូវវស្សា | ព្រៃឈើ |
| ទិន្នផល | ផលត្រីគ្រប់ប្រភេទ | ដំណាំភូមិ-ស្រុក | 1-1,6ត/ហត | សរសរ, ឈើ សត្វព្រៃស្បូវ, វល្លិ | 1-1,5ត/ហត | សរសរ, ឈើ សត្វព្រៃស្បូវ, វល្លិ | 3 ត/ហត | ផល-អនុផល សត្វព្រៃ..... | 3 ត/ហត | ផល-អនុផល សត្វព្រៃ.... |
| សត្វព្រៃ | ពស់, អណ្តើក កន្ធាយ... | ពស់វែក ពស់ថ្លាន់... | សត្វព្រៃ | សត្វព្រៃ | សត្វព្រៃ | សត្វព្រៃ | សត្វព្រៃ | សត្វព្រៃ | សត្វព្រៃ | សត្វព្រៃ |
| ត្រី | ត្រីច្រើនប្រភេទ | | ផ្ទក់, អណ្តែង, ក្តាម កង្កែប, ខ្យង... | ត្រីក្បាល, ត្រីនៅ តាមថ្លុកត្រពាំង | ផ្ទក់, អណ្តែង, ក្តាម កង្កែប, ខ្យង... | ត្រីក្បាល, ត្រីនៅ តាមថ្លុកត្រពាំង | ផ្ទក់, អណ្តែង, ក្តាម កង្កែប, ខ្យង... | ត្រីក្បាល, ត្រីនៅ តាមថ្លុកត្រពាំង | ផ្ទក់, អណ្តែង, ក្តាម កង្កែប, ខ្យង... | ត្រីក្បាល, ត្រីនៅ តាមថ្លុកត្រពាំង |
| សត្វស្រុក | | គោ, ក្របី មាន់, ទា... | គោ, ក្របី មាន់, ទា.. | | គោ, ក្របី មាន់, ទា.. | | គោ, ក្របី មាន់, ទា.. | | គោ, ក្របី មាន់, ទា.. | |
| បញ្ហាជួបប្រទះ | ត្រីខាំមនុស្សខ្សត់ត្រី ,គ្រោះធម្មជាតិ.... | ជំនន់, ជំងឺសត្វ -មនុស្ស | គ្រោះធម្មជាតិ, សត្វល្អិត, សត្វបំផ្លាញ | ការកាប់បំផ្លាញ ព្រៃឈើសត្វព្រៃ | គ្រោះធម្មជាតិ, សត្វល្អិត, សត្វបំផ្លាញ | ការកាប់បំផ្លាញ ព្រៃឈើសត្វព្រៃ | គ្រោះធម្មជាតិ, សត្វល្អិត, សត្វបំផ្លាញ | ការកាប់បំផ្លាញ ព្រៃឈើសត្វព្រៃ | គ្រោះធម្មជាតិ, សត្វល្អិត, សត្វបំផ្លាញ | ការកាប់បំផ្លាញ ព្រៃឈើសត្វព្រៃ |
| ដំណោះស្រាយ | គ្រប់គ្រងដោយ សហគមន៍នេសាទ | [illegible] | ស្រែបណ្តុញទឹក ថ្នាំការពារសត្វ | បង្កើតសហ គមន៍ព្រៃឈើ | ស្រែបណ្តុញទឹក ថ្នាំការពារសត្វ | បង្កើតសហ គមន៍ព្រៃឈើ | ស្រែបណ្តុញទឹក ថ្នាំការពារសត្វ | បង្កើតសហ គមន៍ព្រៃឈើ | គ្មានបញ្ហា | បង្កើតសហ គមន៍ព្រៃឈើ |

រូបភាពទី២

13




រូបភាពទី ៣:ផែនទីធនធានធម្មជាតិភូមិកោះឡារ

14

២.២.៤ ធនធានសង្គម :

ដោយសារភូមិនៅឆ្ងាយពីទីប្រជុំជន ជាទូទៅការព្យាបាលជំងឺគេពឹងផ្អែកច្រើនទៅលើថ្នាំបុរាណដែល ផ្សំនៅក្នុងភូមិ ចំណែកថ្នាំពេទ្យដែលលក់ក្នុងភូមិមានបន្តិចបន្តួច គ្មានការត្រួតពិនិត្យត្រឹមត្រូវទេ។ ភូមិលាតសន្ធឹង តាមបណ្តោយដងទន្លេយ៉ាងវែង ហើយអ្នកភូមិសង់ផ្ទះនៅតាមបណ្តោយភូមិឃ្លាតឆ្ងាយៗពីគ្នា ដូចនេះការទំនាក់ ទំនងនៅក្នុងភូមិទាំងមូលមានការលំបាក។

អ្នកភូមិមានទំនៀមទំលាប់ប្រពៃណីជួយគ្នាទៅវិញទៅមកនៅពេលមានពិធីបុណ្យផ្សេងៗ សង់ផ្ទះ ពិធីឡើងផ្ទះ រៀបអាពាហ៍ពិពាហ៍ និងជួយគ្នាក្នុងពេលមានអាសន្នអន់ក្រ ដូចជាមានជំងឺ និងសំរាលកូនជាដើម។ មេឃុំ មេភូមិ ចាស់ព្រឹទ្ធាចារ្យ គណៈកម្មការអភិវឌ្ឍន៍ ជាមនុស្សគន្លឹះក្នុងការងារអភិវឌ្ឍន៍របស់ភូមិ គេមានតួ នាទីយ៉ាងសំខាន់ក្នុងការងារគ្រប់គ្រង និងការដឹកនាំ ការប្រមូលផ្តុំអ្នកភូមិដើម្បីធ្វើផែនការជាមួយអង្គការ ក្រៅរដ្ឋាភិបាលដើម្បីបង្កើតកម្មវិធីអភិវឌ្ឍន៍ដូចជា ធនាគារស្រូវ ម៉ាស៊ីនបូមទឹក ការព្យាបាលសត្វ ការថែរក្សា ធនធានមច្ឆាជាតិ និងកាកបាទក្រហម។

ដើម្បីសិក្សាលើការទំនាក់ទំនងរវាងអ្នកភូមិជាមួយនឹងអ្នកខាងក្រៅក្រុមការងារបានធ្វើការសិក្សាដាច់ដោយឡែកពីគ្នារវាងក្រុមបុរស និងស្ត្រី (វ៉ែនដ្យាក្រាម )។ ក្រុមការងារបានសំរបសំរួលឱ្យអ្នកភូមិប្រើប្រាស់ក្រដាសដែលមានរាងជារង្វង់មូលមានទំហំ ៣ ខុសគ្នាសំរាប់តាងឱ្យស្ថាប័ន អង្គការ និងបុគ្គលដែលមានការពាក់ពន្ធ័ជាមួយអ្នកភូមិ។ ទំហំក្រដាសតំណាងឱ្យភាពសំខាន់ រីឯចំងាយដែលធៀបទៅនឹងភូមិបង្ហាញពីភាពជិតស្និទ្ធ និងការទំនាក់ទំនងញឹកញាប់ជាមួយអ្នកភូមិ។ នៅលើវ៉ែនដ្យាក្រាមរបស់ក្រុមទាំងពីរនេះបានបង្ហាញឱ្យឃើញការទំនាក់ទំនងរបស់ពួកគាត់ មានភាពដូចគ្នាច្រើនតែក៏បានបង្ហាញ ពីគំនិតខុសគ្នាទៅលើស្ថាប័ន និង បុគ្គលមួយ ចំនួនដែរ។

*មនុស្ស និងស្ថាប័នដែលសំខាន់ជាងគេ*

ទាំងបុរសនិងស្ត្រីបានគិតថា មេភូមិ មេឃុំ ពេទ្យភូមិ ឆ្មបបុរាណ គណៈកម្មការអភិវឌ្ឍន៍ភូមិ គ្រូបង្រៀន សាលារៀន គឺជាមនុស្ស និងស្ថាបន័សំខាន់ ដែលមានទំនាក់ទំនងជិតស្និទ្ធបំផុតជាមួយពួកគាត់។ បុគ្គលនិង ស្ថាប័នទាំងនេះជាអ្នកជួយអ្នកភូមិក្នុងការគ្រប់គ្រងដឹកនាំ កសាង ថែទាំសុខភាព និង អប់រំបណ្តុះបណ្តាលកូនចៅក្នុងការប្រកប របរចិញ្ចឹមជីវិត ជាពិសេសជួយទំនាក់ទំនង និង ដោះស្រាយរាល់បញ្ហាលំបាកផ្សេងៗដែលអ្នកភូមិជួបប្រទះ។

បន្ទាប់មកមានមនុស្ស និងស្ថាបន័មួយចំនួនដែលក្រុមបុរសគិតថាសំខាន់ដែរ តែមានទំនាក់ទំនងមធ្យមដូចជា ប៉ូលីស មេឃុំ ភ្នាក់ងារសុខាភិបាលស្មគ្រ័ចិត្ត និង អ្នកលក់ដូរ។ ប៉ូលីសមានតួនាទីការពារសុវត្ថិភាព និង សន្តិសុខភូមិ មេឃុំ ជួយទំនាក់ទំនងការងារពីឃុំមកភូមិ ភ្នាក់ងារសុខាភិបាល ជួយព្យា

បាលជំងឺ និងធ្វើការផ្សព្វផ្សាយអប់រំផ្នែកសុខភាពដល់អ្នកភូមិ ដោយឡែកមធ្យោបាយដឹកជញ្ជូនបានជួយសម្រួលដល់ការធ្វើដំណើរ និង ដឹកជញ្ជូនកសិផល និងផលិតផលនានាមកកាន់ទីផ្សារ ។

ក្រុមស្ត្រីគិតថាពេទ្យឯកជន អ្នកជិតខាង គណៈកម្មការបុណ្យ ឈ្មួញទិញគោក្របី គ្រូខ្មែរបុរាណសំខាន់ សំរាប់ពួកគាត់ ។ ពេទ្យឯកជនបានបំរើសេវាសុខភាពដល់អ្នកភូមិ អ្នកជិតខាងចេះជួយគ្នានៅពេលរវល់ ដូចជា បុណ្យ និង ពិធីរៀបអាពាហ៍ពិពាហ៍ជាដើម ឈ្មួញទិញគោ ក្របី សំរួលដល់ការលក់សត្វពាហនៈ របស់អ្នកភូមិ នៅពេលពួកគាត់ត្រូវការប្រាក់មកប្រើប្រាស់នៅក្នុងគ្រួសារ គ្រូខ្មែរបុរាណបាន ជួយសង្គ្រោះ អ្នកជំងឺដែលមាន នៅក្នុងភូមិ។ នៅមានមនុស្សសំខាន់ មួយចំនួនទៀតដែលក្រុមបុរសគិតថាសំខាន់ដែរតែពួកគេទាំងនោះស្ទើរ តែមិនដែលមកធ្វើ ការនៅភូមិគាត់ សោះ ដូចជាសាលាស្រុក អង្គការ PFD PM សិទ្ធិមនុស្ស និង ឈ្មួញទិញ កសិផល ។

*មនុស្ស និងស្ថាប័នដែលសំខាន់មធ្យមៈ*

គណៈកម្មការបុណ្យ សាលាឆទាន ពេទ្យសត្វ ឱសថបុរាណ ចុងភៅ ជាងផ្ទះ កាកបាទក្រហម ជាមនុស្សដែលក្រុមស្ត្រី គិតថាសំខាន់មធ្យម ក្រុមទាំងនេះហើយដែលជួយសំរួលដល់ការរស់នៅរបស់ពួកគាត់ ដូចជាទេព្យសត្វភូមិជួយព្យាបាលជំងឺសត្វនៅពេលសត្វឈឺម្តងៗ រីឯគណៈកម្មការបុណ្យវិញបានជួយសំរួលដល់ការធ្វើបុណ្យនៅរដូវភ្ជុំបិណ្ឌ និងពិធីបុណ្យផ្សេងៗ។ ឯបុរសវិញគិតថាឈ្មួញទិញជ្រូក អ្នកទិញសរសរ និង ភ្នាក់ងារដំណាំកសិកម្មជាមនុស្សសំខាន់មធ្យម។ ឈ្មួញទិញជ្រូកតែងតែមកទិញជ្រូកដល់ផ្ទះ នៅពេលដែលពួកគាត់ ចិញ្ចឹមបានហើយមិនចាំបាច់ឱ្យពួកគាត់ដឹកជញ្ជូនមកទីផ្សារ ដូចគ្នានេះដែរមានអ្នកទិញសរសរបានមកប្រមូល ទិញសរសរដែលគាត់កាប់ពីព្រៃ ។

*មនុស្ស និងស្ថាប័នដែលមិនសូវសំខាន់*

មនុស្សនិងសាប័នមួយចំនួនដែលមិនមានភាពស្និទ្ធស្នាលជាមួយអ្នកភូមិគឺ តុលាការ សាលាខេត្ត។ ពួកអ្នក ទាំងអស់នេះមិនសូវសំខាន់សំរាប់គាត់ទេ ព្រោះមានការលំបាក ក្នុងការទំនាក់ទំនង។




រូបភាពទី៤: ផែនទីសង្គមភូមិកោះច្បារ



រូបភាពទី ៤ ៖ ស្ថាប័នទំនាក់ទំនង

ផែនដ្យាក្រាមស្ថាប័ននិងទំនាក់ទំនងផ្នែកស្ត្រី




រូបភាពទី ៦ ៈស្ថាប័នទំនាក់ទំនង

19

**២.២.៥ ធនធានហិរញ្ញវត្ថុ :**

ជាទូទៅអ្នកភូមិរកប្រាក់ចំណូលដោយពឹងផ្អែកលើការលក់កសិផល អនុផលព្រៃឈើ និង ផលនេសាទ ជាដើម។ ក្រុមអ្នកធូរធារ និង អ្នកមធ្យមមានលទ្ធភាពច្រើនក្នុងការធ្វើស្រែចំការ ប្រមាញ់សត្វព្រៃ កាប់ឈើ និងនេសាទ ដោយពួកគេមានសំភារៈនិង ឧបករណ៍គ្រប់គ្រាន់សំរាប់ប្រើប្រាស់ក្នុងការប្រកបមុខរបរនោះ។ ក្រៅពីនេះពួកគេក៏មានចំណូលមកពីការលក់សត្វចិញ្ចឹម ដូចជា គោ ក្របី ជ្រូក មាន់ ទា ផងដែរ។

ចំពោះអ្នកក្រីក្រ និងអ្នកទីទ័លក្រវិញប្រកបមុខរបរចិញ្ចឹមជីវិតដោយពឹងផ្អែកលើការស៊ីឈ្នួលធ្វើការឱ្យគេដែលអាចបានប្រាក់ចំណូលពី ២៥០០- ៣០០០រៀលក្នុងមួយថ្ងៃ។ ក្រៅពីនេះមានអ្នកខ្លះទៅប្រកបមុខ របរផ្សេងៗ ទៀតដូចជាការប្រមាញ់សត្វព្រៃ កាប់ឬស្សី និងស៊ីឈ្នួលកាប់ឈើ។ ការរកចំណូលរបស់អ្នកក្រីក្រ និង អ្នកទីទ័លក្រនៅក្នុងភូមិ មានការលំបាក ហើយរកប្រាក់ចំណូលបានតិចតួចបំផុត គេស្ទើរតែគ្មាន លទ្ធភាព ប្រមូលផលលើធនធានធម្មជាតិដែលភូមិមានដូចជាត្រី និងផលអនុផលព្រៃឈើ ព្រោះគាត់គ្មានឧបករណ៍ និង សំភារៈដើម្បីប្រកបមុខរបរនេះ។

*តារាងទី៤:* **ធនធានសំខាន់ៗនាំឲប្រាំក្នុងភូមិកោះច្បារ**

| ធនធានមនុស្ស | ធនធានហេដ្ឋារចនាសម្ព័ន្ធ | ធនធានធម្មជាតិ | ធនធានសង្គម | ធនធានហិរញ្ញវត្ថុ |
|---|---|---|---|---|
| - មេភូមិ មេឃុំ ,គណៈកម្មការអភិវឌ្ឍន៍ភូមិ ៥នាក់/ស្រី២នាក់<br>-គ្រូបង្រៀន ២នាក់<br>-គណៈកម្មការជង្រុកស្រូវ៥នាក់/ស្រី២ នាក់<br>-គ្រូខ្មែរ ២នាក់ ពេទ្យភូមិ១នាក់ស្រី ឆ្មបបុរាណ៦នាក់ ជាងផ្ទះ ២នាក់<br>- គណៈកម្មការម៉ាស៊ីនបូមទឹក៥ន/ស្រី២នាក់<br>- អ្នកឡើងត្នោត៤នាក់<br>- ភ្នាក់ងារស្ម័គ្រចិត្តសុខាភិបាល២ន/ស្រី១ន<br>-គណៈកម្មការបុណ្យ<br>- គណៈកម្មការនេសាទ៩នាក់/ស្រី៤នាក់<br>- អ្នកបិតស្រា ៧ នាក់<br>- អ្នកលក់ដូរតិចតួច៥ផ្ទះ<br>- ចុងភៅ១នាក់<br>- អ្នកស្ម័គ្រចិត្តកាកបាទក្រហម២ នាក់/ស្រី១ន | - អាយកូម ១គ្រឿង<br>- មានផ្លូវលំក្នុងភូមិ ១ខ្សែ<br>- សាលាបឋមសិក្សា ១ខ្នង<br>- សាលាឆទាន ១ខ្នង<br>- តូបចាប់ហួយ ៥កន្លែង<br>- ម៉ាស៊ីនកិនស្រូវ ៥ គ្រឿង<br>- ទំនប់មានចំនួន៣កន្លែង ទំនប់ស្រែវែង ទំនប់ខ្ទម្ព ទំនប់ស្រែក្រសាំង<br>- ផ្លូវរទេះ ១ខ្សែ<br>- ម៉ាស៊ីនបូមទឹក ៣គ្រឿង ១គ្រឿងបានមកពីអង្គការ OCAA | - ទន្លេមេគង្គ<br>- ព្រែកអូរស្វាន ព្រែកអូរតាណើង ព្រែកអូរត្នោត អូរកាច់ព្រួល<br>- ព្រៃឈើ សត្វព្រៃ<br>- ដីចំការ<br>- ដីស្រែវស្សា ១៣៩ហិកតា<br>- ដីភូមិតាមមាត់ទន្លេ និងដីដាំដំណាំហូបផ្លែ<br>- វារីជាតិ ជាពិសេសត្រី<br>- ព្រៃលិចទឹក<br>- ផល-អនុផលព្រៃឈើ | -សាសនាព្រះពុទ្ធ<br>-គោរពចាស់ព្រឹទ្ធាចារ្យ<br>- ប្រពៃណីជួយគ្នាទៅវិញទៅមក<br>-ពិធីបុណ្យផ្សេងៗ<br>-ការសាមគ្គីគ្នា<br>-មានការដឹកនាំធ្វើការងារផ្សេងៗ របស់ចាស់ព្រឹទ្ធាចារ្យ និង គណៈកម្មការអភិវឌ្ឍន៍ភូមិ | - លក់កសិផល<br>- លក់សត្វចិញ្ចឹមគោ ក្របី ជ្រូក មាន់<br>- ស៊ីឈ្នួល២៥00៛-៣000៛/១ថ្ងៃ<br>- លក់ត្រី២000៛-២៥00៛/១Kg<br>-ជួលម៉ាស៊ីនបូមទឹកតំលៃ ៣000៛/១ម៉ោង<br>-ជួលម៉ាស៊ីនបូមទឹករបស់អង្គការ OCAAតំលៃ៨000៛/១ម៉ោង<br>-ឥណទានស្រូវអង្គការ OCAA ១ថាំង ការចំនួន១កន្តាំង<br>-ជួលគោ ក្របី ធ្វើស្រែ១រដូវ ស្មើនឹង ១៥ថាំង<br>-ជួលដីស្រែ១រដូវពី២៥-៣0ថាំង |

### ធនធានទាំងប្រាំតាងដោយរូបភាពបញ្ចកោណ




**H** ធនធានមនុស្ស **N** ធនធានធម្មជាតិ **F** ធនធានហិរញ្ញវត្ថុ **P** ធនធានហេដ្ឋារចនាសម្ព័ន្ធ **S** ធនធានសង្គម

- ធនធានមនុស្ស:យើងមិនឃើញសញ្ញាណាមួយដែលបង្ហាញពីការអភិវឌ្ឍន៍នោះឡើយ ព្រោះអ្នកភូមិទូទៅសឹងតែមិនអាចឆ្លងផុតអនក្ខរភាពផង គេអាចរៀនបានត្រឹមថ្នាក់ទី៣ ដែលមាននៅក្នុងភូមិ ។
- ធនធានធម្មជាតិកំពុងតែមានការថយចុះជាពិសេសព្រៃឈើ សត្វព្រៃ និងធនធានមច្ឆាជាតិ ព្រមជាមួយនិងកំណើនមនុស្សចេះតែកើនឡើងយ៉ាងច្រើនដែលទាមទារឱ្យពួកគាត់ពង្រីកផ្ទៃដីដាំដុះ និងធ្វើនេសាទហួសកំរិត និង ការកាប់ព្រៃឈើដែលស្ថិតនៅក្នុងភូមិរបស់គាត់ ។
- ធនធានហិរញ្ញវត្ថុរបស់អ្នកភូមិទូទៅគឺពឹងផ្អែកលើកសិផល និងការប្រមូលផលពីធម្មជាតិ ដូចនេះវាមានការទាក់ទងទៅនឹង ធនធានធម្មជាតិ កត្តាធម្មជាតិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ប្រសិនបើធនធានធម្មជាតិមានការថយចុះហើយ ការរកប្រាក់ចំណូលរបស់អ្នកភូមិក៏អាចថយចុះផងដែរ ។
- ធនធានហេដ្ឋារចនាសម្ព័ន្ធសាលារៀនសាលាឆទាន ផ្លូវគមនាគន៍មិនបានឆ្លើយតបទៅនឹងតំរូវការរបស់អ្នកភូមិទេ ។អ្នកភូមិមានការលំបាកក្នុងការធ្វើទំនាក់ទំនងជាមួយអ្នកខាងក្រៅ ហើយរាល់កសិផលនិងផលិតផលនានារបស់អ្នកភូមិមានតំលៃថោកជាងទីផ្សារដល់ទៅ ៥០%ព្រោះពិបាកក្នុងការដឹកជញ្ជូន ។
- ធនធានសង្គម : អ្នកភូមិមានការទំនាក់ទំនងគ្នាល្អ សាមគ្គីគ្នា ដូចជានៅពេលមានបុណ្យទាន និងពិធី ផ្សេងៗ ជាពិសេសការគោរពចាស់ព្រឹទ្ធាចារ្យនៅក្នុងភូមិ ។ចំពោះរដ្ឋអំណាចមូលដ្ឋានភូមិមានការទំនាក់ ទំនងល្អ ដោយមាន គោរពគ្នាទៅវិញទៅមកហើយផ្តល់ភាពងាយស្រួលសំរាប់អ្នកខាងក្រៅ ដើម្បី សហការធ្វើការងារផ្សេងៗជាមួយ អ្នកភូមិប៉ុន្តែអ្នកភូមិមិនសូវមានទំនាក់ទំនងជាមួយរដ្ឋអំណាចថ្នាក់ លើ ឡើយ ។

## ២-៣ ភាពងាយរងគ្រោះ

### ២-៣-១ កសិកម្មនិងរដូវកាល

សកម្មភាពបង្កបង្កើនផលការងារសង្គម និងការប្រែប្រួលក្នុងរយៈពេលមួយឆ្នាំត្រូវបានបង្ហាញនៅក្នុងដ្យាក្រាមរដូវកាលដែលធ្វើឡើងដោយក្រុមបុរស និងស្ត្រីដាច់ដោយឡែកពីគ្នា។ ក្រុមសិក្សាបានសំរបសំរួលឱ្យអ្នកភូមិដាក់គ្រាប់ពោតដើម្បីសំគាល់ភាពមមារ ញឹកមិនសូវរវល់ និង ទំនេរតាមខែនីមួយៗដោយកំណត់ថា ៥ គ្រាប់ សំរាប់ការមមារញឹកខ្លាំងហើយមិនសូវ រវល់ ៤ ឬ ៣គ្រាប់ទៅតាមលំដាប់រហូត ដល់មិនមានសកម្មភាពសោះទុកនៅទំនេរ។ ក្រុមទាំងពីរបានជ្រើសរើសយកខែតាមប្រតិទិនចន្ទគតិដែលគេនិយមហៅថាខែ ខ្មែរមកប្រើដោយកំណត់យកខែចែត្រជាខែទីមួយ ដែលត្រូវនឹងខែ មេសា។

នៅក្នុងសកម្មភាពបង្កបង្កើនផលអ្នកភូមិមានការរវល់ស្ទើរពេញមួយឆ្នាំហើយយើងសង្កេតឃើញមានការងារខ្លះ បុរស និងស្ត្រីធ្វើការងារដូចគ្នា តែពេលខ្លះគេធ្វើការងារខុសគ្នា។ ស្ត្រីចូលរួមការងារធ្វើស្រែវស្សានៅចុងខែមេសា ពួកគាត់ជាអ្នកកាប់ព្រៃ ហើយបុរសទៅធ្វើការភ្ជួរាស់ដីនៅខែ ឧសភា គឺនៅក្រោយពេលស្ត្រីកាប់ឆ្ការព្រៃហើយ ពួកគាត់បន្តរធ្វើការថែទាំរហូតដល់ប្រមូលផល។ នៅពេលដែលទំនេរពីការងារដាំដុះគេទៅកាប់ឆ្ការព្រៃ គាស់គល់ដើម្បីពង្រីកដីកសិកម្ម និងធ្វើការងារផ្សេងៗទៀតដើម្បីចិញ្ចឹមជីវិតដូចជា នេសាទ ឡើងត្នោត រុករកផល-អនុផលព្រៃឈើ។ គេអាចធ្វើការនេសាទពេញមួយឆ្នាំ ប៉ុន្តែមមាញឹកខ្លាំងក្នុងខែ មិនា ខែមេសា ពីព្រោះពេលនេះពួកគាត់ទំនេរពីការងារផ្សេងៗទៀតទៀត។

ចំពោះស្ត្រីវិញគេធ្វើប្រហុក ផ្អក នៅខែឧសភា ដល់ ខែមិថុនា ជារៀងរាល់ឆ្នាំ ពីព្រោះពេលនេះទឹកចាប់ផ្តើមឡើងត្រីក៏ចុះពីអន្លង់នានាឆ្ពោះទៅតំបន់វាលទំនាប និងតំបន់ព្រៃលិចទឹកដើម្បីពងកូន និងស៊ីចំណី។ ក្រៅពីនេះស្ត្រីមាន ការងារផ្សេងទៀតដូចជា ច្រូតស្បូវ ច្រូតស្រូវ និង ថែទាំកូន។

ក្រុមបុរស និង ស្ត្រីបានបង្ហាញអំពីជំងឺមនុស្ស ជំងឺសត្វ និងភាពខ្វះខាតស្បៀងឱ្យក្រុមការងារដឹង។ ជំងឺមនុស្ស និងសត្វកើតមានសឹងពេញមួយឆ្នាំ ជំងឺសត្វច្រើនកើតនៅខែវស្សា។ បញ្ហាខ្វះស្បៀងច្រើននៅចន្លោះ ខែឧសភាដល់ខែកញ្ញាគឺនៅក្នុងរដូវវស្សា។

### ដ្យាក្រាមរដូវកាលនៅភូមិកោះខ្សាររបស់ក្រុមបុរស

| សកម្មភាពការងារ | ១ ចែត្រ | ២ ពិសាខ | ៣ ជេស្ឋ | ៤ អាសាឍ | ៥ ស្រាពណ៍ | ៦ ភទ្របទ | ៧ អស្សុជ | ៨ កត្តិក | ៩ មិគសិរ | ១០ បុស្ស | ១១ មាឃ | ១២ ផល្គុន |
|---|---|---|---|---|---|---|---|---|---|---|---|---|
| អាកាសធាតុ | ក្តៅ | | | ភ្លៀង | | | | រងារ | | | | ក្តៅ |
| ធ្វើស្រែវស្សា | | ●● | ●●● | ●●●●● | ●●●●● | ●● | ●● | ●●●●● | ●●●●● | ●● | | |
| ស្រែបណ្តុញទឹក | | | | | ●● | ●●●● | ●●●●● | ●●● | ●●● | ●●●● | ●●●●● | |
| ចំការស្រូវ | ●●●●● | ●● | ●● | ●●●● | ●●●●● | | | | | | | |
| ពោត | ●●●●● | ●● | ●● | ●●●● | | | | | | | | |
| ដំឡូងគ | ●●●●● | ●● | ●● | ●● | ●● | ●● | ●● | ●● | ●● | ●● | ●●●●● | ●●●●● |
| ស៊ីឈ្នួល | | | | | ●●●●● | ●●●●● | | | | ●●●●● | ●●●●● | |
| ស្ករត្នោត | | | | | | | | | ●● | ●●● | ●●●●● | ●●●●● |
| កាប់សរសរ-ឈើ | | | | | | | | | ●● | ●● | | |
| កាប់ឫស្សី | | | | | | ●● | ●● | | | | | |
| នេសាទត្រី | ●●●●● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ●●●●● |

រូបភាពទី៧

25

ក្រុមចុះស

| សមត្ថភាពការងារ | ១ ចេត្រ | ២ ពិសាខ | ៣ ជេស្ឋ | ៤ អាសាឍ | ៥ ស្រាពណ៍ | ៦ ភទ្របទ | ៧ អស្សុជ | ៨ កត្តិក | ៩ មិគសិរ | ១០ បុស្ស | ១១ មាឃ | ១២ ផល្គុន |
|---|---|---|---|---|---|---|---|---|---|---|---|---|
| អាកាសធាតុ | ក្តៅស្ងួត | | | វស្សា | | | | រងា | | | | ក្តៅ |
| សណ្តែកបាយ | | | | | | ●●●●● | ●● | ●● | ●●●●● | | | |
| ជំងឺមនុស្ស | ●● | ●●●●● | ●● | ●●●● | ● | ●●●●● | ●● | ●●● | ● | ● | ● | |
| ជំងឺសត្វ | ●●●●● | ●●●● | ●● | ●● | ●● | ●●●●● | | | | | | |
| បញ្ហាទឹក | | | | | | | | ●●●● | ●●●● | ●●●●● | ●● | |
| ខ្វះស្បៀង | | ●● | ●● | ●● | ●●●● | ●●●●● | | | | | | |
| ឥណទាន(ភូមិ) | | ●● | ●● | ●● | ●●●● | ●●●●● | ● | ● | ● | ●●●●● | | |
| ចំណូលថវិកា | ●●●●● | | | | ●●●●● | ●●●●● | | | | ●●●●● | | |
| អាពាហ៍ពិពាហ៍ បុណ្យ | ●●●●● | ●●●●● | ● | ● | ● | ●●●●● | ●● | ●● | ●● | ●●●●● | ●● | ●●●●● |

ប្រភពទី៧ គ

26

## ដ្យាក្រាមរដូវកាលនៅភូមិកោះខ្សាររបស់ក្រុមស្ត្រី

| សកម្មភាពការងារ | ១ ចែត្រ | ២ ពិសាខ | ៣ ជេស្ឋ | ៤ អាសាឍ | ៥ ស្រាពណ៍ | ៦ ភទ្របទ | ៧ អស្សុជ | ៨ កត្តិក | ៩ មិគសិរ | ១០ បុស្ស | ១១ មាឃ | ១២ ផល្គុន |
|---|---|---|---|---|---|---|---|---|---|---|---|---|
| អាកាសធាតុ | ក្តៅ | | | ភ្លៀង | | | រងារ | | | | | ក្តៅ |
| ធ្វើស្រែវស្សា | ●●● | ●●● | ●●●● | ●●●●● | | ●●●● | ●● | ●● | ●●●●● | ●●●●● | ● | ● |
| ពោត | ●●●●● | ●●●●● | ●●● | ●●●● | | | | | | | | |
| សណ្តែកបាយ | | | | | ●●●● | ●● | ●● | ●●●●● | | | | |
| ច្រូតស្រូវ | | | | | | | | ●●●● | ●●● | ●●● | ●● | ●● |
| ធ្វើប្រហុក | | | ●● | ●● | | | | | | | | |
| ពិធីបុណ្យ | ●●●●● | ●● | | | | ●●●●● | ●●● | ●● | | | | |
| រៀបការ | | ●●● | | | | | | | | ●●● | ●●● | ●●● |
| ជំងឺមនុស្ស | | ●●●●● | ●●●● | ●● | ●●●●● | ●●●●● | ●●● | ●● | ● | ● | ● | ● |
| ជំងឺសត្វពាហនៈ | | ●●●●● | ●●●● | ●●● | | | | | | | | |
| ខ្វះស្បៀង | | | | ●● | ●●● | ●●●●● | | | | | | |

27

រូបភាពទី ៨

## ២-៣-២ និន្នាការនិងការប្រែប្រួល

ការប្រែប្រួលមួយចំនួនមានការទាក់ទងទៅនឹងការចិញ្ចឹមជីវិតរបស់អ្នកភូមិកោះច្បារ។ អ្នកភូមិបានតាងការប្រែប្រួលទាំងនេះលើដ្យាក្រាម (មើលដ្យាក្រាម) ដូចជាផ្ទៃដីស្រែវស្សា សត្វព្រៃ ព្រៃឈើ ទឹកជំនន់ ផលត្រី សត្វផ្សោត សាលារៀន សហគមន៍ កំណើនប្រជាជន វត្តអារាម និង ជំងឺគ្រុនចាញ់។

*ដីស្រែវស្សា :*

ភូមិកោះច្បារ ជាភូមិនៅឆ្ងាយពីទីប្រជុំចន ក្នុងតំបន់ព្រៃស្រោងដែលមានផ្ទៃដីធំល្វឹងល្វើយ នេះគឺជាធនធានធម្មជាតិដ៏សំខាន់របស់ភូមិ ដែលផ្តល់លទ្ធភាពឱ្យអ្នកភូមិ ក្នុងការកាប់ឆ្ការព្រៃ ពង្រីកដីដាំដុះ។ នៅក្នុងដ្យាក្រាម បានបង្ហាញឱ្យឃើញថាផ្ទៃដីស្រែរបស់អ្នកភូមិមានការកើនឡើងជាលំដាប់ ការកើនឡើងនេះកើតមានស្របគ្នាទៅនឹងកំណើនប្រជាជននៅក្នុងភូមិ។

នៅប៉ុន្មានឆ្នាំចុងក្រោយនេះដោយសារបញ្ហាទឹកជំនន់ អ្នកភូមិបានផ្លាស់យុទ្ធសាស្រ្តក្នុងការធ្វើស្រែវស្សាទៅធ្វើស្រែបណ្តែញទឹក និងធ្វើការកាប់ឆ្ការព្រៃនៅតំបន់ខ្ពស់ឆ្ងាយពីទន្លេ ដែលមិនឋិតក្រោមឥទ្ធិពលទឹកជំនន់។ ប៉ុន្តែនៅពេលគេទៅធ្វើស្រែនៅឆ្ងាយគេជួមនឹងបញ្ហាសត្វបំផ្លាញ ជាពិសេសជ្រូកព្រៃ និងជួនកាលក៏មានបញ្ហាខ្វះទឹកដែរ។

*កំណើនប្រជាជន :*

មនុស្សចាស់ៗក្នុងភូមិចាំបានថា ឆ្នាំ១៩៣០-១៩៥០ ភូមិមានប្រជាជនរស់នៅចំនួន ១៨គ្រួសារ។ ពួកគេរស់នៅរាយប៉ាយក្នុងភូមិ ដោយប្រកបរបរធ្វើស្រែ ចំការ បរបាញ់សត្វ រុករកផល អនុផលព្រៃឈើ និងនេសាទត្រី។ ចំនួនប្រជាជននៅក្នុងភូមិចេះតែកើនឡើង នៅក្នុងចន្លោះឆ្នាំ ១៩៦០-៧០ គេនៅចាំបានថាមានប្រជាជនរស់នៅក្នុងភូមិ ៧២គ្រួសារ។

ចំនួនអ្នកភូមិមានការថយចុះវិញនៅចន្លោះឆ្នាំ ១៩៧០-៨០។ គេចាំបានថានៅក្នុងឆ្នាំ ១៩៧៩ អ្នកភូមិ មានតែ ៣០គ្រួសារទេ ពួកគេជាអ្នកសេសសល់ពីការស្លាប់ដោយសារសង្គ្រាម ពួកប៉ុល ពតសំលាប់ និងមួយចំនួនជន្លាសចេញពីភូមិឋាន។

ចាប់ពីឆ្នាំ ១៩៨០ មកចំនួនប្រជាជនមានការកើនឡើងជាលំដាប់ រហូតមកដល់បច្ចុប្បន្ននេះអ្នកភូមិ មានចំនួន ១៤២គ្រួសារ ហើយពួកគេនៅតែបន្តរប្រកបរបរចិញ្ចឹមជីវិតដូចពីមុនមកដែល។

អ្នកភូមិបានទទួលស្គាល់ដែរថា វាពិតជាមានការប៉ះពាល់ដល់ធនធានធម្មជាតិ នៅពេលដែលមនុស្ស កើនឡើងទាមទារឱ្យមានតំរូវការប្រើប្រាស់ធនធានខ្ពស់ ដែលជំរុញឱ្យមានការប្រមាញ់សត្វព្រៃ ការនេសាទ ការកាប់ព្រៃឈើពង្រីកដីកសិកម្ម និងកាប់ឈើលក់ ដូចនេះយើងសង្កេតឃើញថាធនធានធម្មជាតិរបស់គាត់កំពុងតែថយចុះយ៉ាងខ្លាំង។

*ផលត្រីក្នុងធម្មជាតិ*

ផលត្រីក្នុងធម្មជាតិក៏មានការថយចុះដូចជាធនធានធម្មជាតិផ្សេងៗទៀតដែរ។ នៅក្នុងកំឡុងពេលឆ្នាំ ១៩៦០-៧០ត្រីនៅតាមទន្លេ បឹងមានច្រើនណាស់ នៅពេលនោះគ្មានការនេសាទតាមរបៀបប្រើខ្សែភ្លើងឆក់ និង បោកគ្រាប់ឡើយ ពោលគឺអ្នកភូមិនេសាទត្រីដោយប្រើប្រាស់ឧបករណ៏ប្រពៃណីជាលក្ខណៈគ្រួសារ ដូចជា សន្ទូច មង សំណាញ់ លប ទ្រូ ចាន់។ល។ ស្ថានភាពសំបូរត្រីនេះបន្តរហូតដល់ឆ្នាំ ១៩៨០ ប៉ុន្តែវាមានការថយចុះ ប្រមាណជា ៥០%នៅចនោះឆ្នាំ ១៩៨០-៨៥ បើប្រៀបធៀបទៅ នឹងទសវត្សឆ្នាំ ៦០-៨០ ការថយចុះនេះ បណ្តាលមកពីការនេសាទដោយប្រើឧបករណ៏ខុសច្បាប់ដូចជា ម៉ាស៊ីនឆក់ បោកគ្រាប់បែក និងបិទអូរជាដើម។ ដល់ ឆ្នាំ១៩៩០-២០០០ត្រីស្ថិតក្នុងកំរិតមានស្ថេរភាពដោយពេលនោះមានការ ភូមិមានសហគមន៏នេសាទ និងមានកិច្ចសហការរវាងសមត្ថកិច្ចនេសាទ។ ម្យ៉ាងឧបករណ៏នេសាទ ត្រូវបានកំណត់ដោយបង្កើតជាសហគមន៏ នេសាទ ពិសេសទៅទៀតនេះការកាត់ឡូត៏នេសាទប្រគល់ជូនសហគមន៏ជាអ្នកគ្រប់គ្រង។ ការកើនឡើងនៃ ចំនួនប្រជាជននាំឱ្យមានតំរូវការហូបត្រីកាន់តែខ្ពស់វាក៏ជាកត្តាជំរុញឱ្យផលត្រីថយចុះផងដែរ។

*សត្វផ្សោត ៈ*

សត្វផ្សោតគឺជាប្រភេទសត្វ ដែលបច្ចុប្បន្ននេះមានការចាប់អារម្មណ៏ពីអ្នកទេសចរណ៏ជាតិ និង អន្តរ ជាតិ។ ផ្សោតមាននៅតាមទន្លេ ក្នុងអន្លង់ជ្រៅៗ កាលពីអំឡុងឆ្នាំ១៩៦៥-៧០។ ឆ្នាំ១៩៧០-៨០ មានបន្តិច បន្តួច ដល់ឆ្នាំ១៩៨០-២០០២ គឺគ្មានផ្សោតក្នុងដែននេសាទភូមិកោះច្បារតែម្តង។ ការបាត់បង់ផ្សោតទាំងស្រុង ពីដែលនេសាទភូមិកោះច្បារនេះបណ្តាលមកពីការនេសាទដោយប្រើម៉ាស៊ីនឆក់ និងជាពិសេស ទៅទៀតនោះគឺ ការបោកគ្រាប់បែកដែលធ្វើឱ្យស្លាប់ផ្សោត និងផ្សោតដែលនៅសេសសល់ភ័យមិនហ៊ាននៅទី នោះទៀត។

*ការបាត់បង់ព្រៃឈើ ៈ*

ថ្វីត្បិតតែតំបន់នេះត្រូវបានគេទទួលស្គាល់ថាជាតំបន់សំបូរព្រៃឈើ តែវាក៏មានការថយចុះជា លំដាប់ ដែរ។ កត្តាសំខាន់ដែលជំរុញឱ្យមានការបាត់បង់ព្រៃឈើនេះគឺការកាប់ឈើលក់តែម្តង ជាពិសេសក្នុងកំឡុងឆ្នាំ ១៩៨០-០០។ អ្នកភូមិបាននិយាយថានៅចន្លោះឆ្នាំ ១៩៩៣-០១ មានក្រុមហ៊ុនមកកាប់ឈើនៅក្នុងភូមិគាត់ គេបានកាប់ឈើដឹកចេញពីភូមិយ៉ាងច្រើនសន្ធឹកសន្ធាប់ បច្ចុប្បន្ននេះក្រុមហ៊ុននេះបានចេញពីភូមិទៅហើយមាន តែពួកអ្នកភូមិកាប់ឈើលក់ ដោយប្រើឧបករណ៏កាំបិត ពូថៅ គេកាប់សំរាប់ប្រើប្រាស់ នៅក្នុងមូលដ្ឋាន និងលក់ បន្តិចបន្តួច។

*ការបាត់បង់សត្វព្រៃ*

ទន្ទឹមនឹងការកាប់ព្រៃឈើ ការប្រមាញ់សត្វព្រៃក៏មានសភាពខ្លាំងក្លាដែរ ដូចនេះសត្វព្រៃមានការបាត់ បង់ស្របគ្នាទៅនឹងព្រៃឈើដែលជាជំរករបស់វា។ អ្នកភូមិនិយាយថាក្នុងកំឡុងឆ្នាំ ១៩៥០-៦០ នៅក្នុងព្រៃ

សំបូរទៅដោយសត្វ ដូចជា ក្តាន់ ឈ្លូស ប្រើស រមាំង ខ្ទីង ទន្សោង ជ្រូក។ ល។ ក្នុងពេលសង្គ្រាមពីឆ្នាំ ១៩៧០-៧៣ សត្វព្រៃមានការថយចុះបន្តិចដោយសារមានយន្តហោះទំលាក់គ្រាប់បែកនៅក្នុងព្រៃធ្វើឱ្យសត្វទាំងនោះស្លាប់ ហើយក៏មានការប្រមាញ់ពីមនុស្សផងដែរ។ ឆ្នាំ១៩៧៣-៧៥ សត្វចំនួនសត្វបានកើនឡើងវិញបន្តិចព្រោះពេលនោះគ្មានសង្គ្រាម និងការប្រមាញ់សត្វលក់ទេ។ ឆ្នាំ១៩៧៩-២០០០ សត្វមានការថយចុះយ៉ាងខ្លាំងដោយសារមានក្រុមហ៊ុនកាប់ឈើ និងមានការប្រមាញ់ដោយប្រើកាំភ្លើង។ ចំនួនសត្វព្រៃមានការកើនឡើងវិញ ជាពិសេស ជ្រូកព្រៃ ព្រោះថារាជរដ្ឋាភិបាលបានចេញនូវគោលនយោបាយដកហូតអាវុធ និងមានការចាត់វិធានការណ៍ តឹងរឹងទប់ស្កាត់ការប្រមាញ់សត្វព្រៃមកលក់នៅទីក្រុង និងទីប្រជុំជននានា។ តាមពតិមានអ្នកភូមិ បានឱ្យដឹងថាក្នុង ភូមិសព្វថ្ងៃគេឃើញមានសត្វខ្ទីង៣ក្បាល ទន្សោង១១ក្បាល ជ្រូកព្រៃ និងស្វាមានរាប់ពាន់ក្បាល និងសត្វផ្សេងៗទៀត។

*សាលារៀនក្នុងភូមិ :*

ក្នុងភូមិមានសាលាបឋមសិក្សា ១ខ្នង មាន២បន្ទប់ សិស្សរៀនបាន ៣ថ្នាក់ បច្ចុប្បន្នមានសិស្សចូលរៀន ១២៣នាក់។ អ្នកភូមិបានអោយដឹងថា នៅឆ្នាំ១៩៧៩-៩៥ភូមិមានសាលារៀន១ខ្នង ដែលមានដំបូលស្បូវ។ ដល់ឆ្នាំ ១៩៩៥-២០០២ អ្នកភូមិបានជួសជុលសាលារៀននោះដោយប្រកក្បឿងជំនួសវិញ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយសាលារៀននេះអាចបំរើឱ្យសិស្សចូលរៀនបានត្រឹមតែថ្នាក់ទី ៣ ដដែល។

*ការបង្កើតសហគមន៍ :*

តាមការសិក្សាបានឱ្យដឹងថាក្នុងភូមិមានសហគមន៍នេសាទ ជង្រុកស្រូវអភិវឌ្ឍន៍ភូមិ ម៉ាស៊ីនបូមទឹក ពេទ្យសត្វ កាកបាទក្រហមស្ម័គ្រចិត្ត ភ្នាក់ងារសុខាភិបាល និងឆ្មបភូមិ ។ អ្វីដែលបាន ពិពណ៌នាខាងលើគឺបានចាប់ផ្តើម ដំណើរការ ពីឆ្នាំ ១៩៩៥-០២ ក្រោមការគាំទ្ររបស់អង្គការ CAA ។

*វត្តអារាម*

ចាស់ៗនៅក្នុងភូមិដែលមានអាយុប្រហែលពី ៦០-៧០ឆ្នាំបានឱ្យដឹងថាក្នុងភូមិមានសាលាឆទាន១ខ្នង ទុកសំរាប់ធ្វើបុណ្យទាន និងសមាទានសីល។ ពួកគាត់បានបន្ថែមឱ្យដឹងថាកាលពីក្នុងអំឡុងឆ្នាំ ១៩៦០-៧០ភូមិមានសាលាឆទានមួយ និងកុដិមួយសំរាប់ទុកគោរពបូជា ពីព្រោះអ្នកភូមិសុទ្ធតែជាអ្នកគោរពព្រះពុទ្ធសាសនា ហើយថែមទាំងមានព្រះសង្ឃទៀតផង។ បច្ចុប្បន្ននេះមានតែសាលាឆទានមួយតែគ្មានព្រះសង្ឃគង់នៅទេ ដល់ពេលរដូវបុណ្យទាន ពួកគាត់ត្រូវទៅនិមន្តព្រះសង្ឃ ពីវត្តខាងក្រៅ ភាគច្រើនពួកគាត់និមន្តលោកពីវត្តសំបូរ។

*បញ្ហាទឹកជំនន់ :*

អ្នកភូមិបាននិយាយថាកាលពីដើម ភូមិគាត់មិនដែលជួបគ្រោះទឹកជំនន់ទេ យូរៗ មានទឹកជំនន់លិចភូមិម្តង។ ពួកគាត់នៅចាំបានថាឆ្នាំ ១៩៧៨មានជំនន់ម្តង ដលឆ្នាំ១៩៨៤ មានម្តងហើយ ឆ្នាំ១៩៩៦ម្តងទៀត។

ប៉ុន្តែនៅពេលប្រហែលបី បួនឆ្នាំចុងក្រោយនេះមានជំនន់ជាប់ៗគ្នា តែម្តងដែលចោតជាបញ្ហាដល់ការចិញ្ចឹមជីវិត ជាពិសេសការធ្វើស្រែវស្សា ដំណាំភូមិ ផ្ទះសំបែង គោ ក្របី ជួបបញ្ហាលំបាកក្រៃលែង។ ទឹកជំនន់ធ្វើឱ្យពួកគាត់ ខ្វះស្បៀង ហើយគាត់ត្រូវផ្លាស់ប្តូរយុទ្ធសាស្ត្រពីការធ្វើស្រែវស្សា ទៅធ្វើស្រែបណ្តែញទឹក និងទៅកាប់ឆ្ការព្រៃនៅឆ្ងាយពីទន្លេដើម្បីធ្វើស្រែ ។

បញ្ហាជំងឺគ្រុនចាញ់:

ជាទូទៅអកភូមិនៅតំបន់ខ្ពង់រាបដាច់ស្រយ៉ាលតែងតែទទួលរងគ្រោះពីជំងឺគ្រុនចាញ់ ក៏ដូចជាអ្នកភូមិកោះច្បារដែរគឺតែងតែរងគ្រោះដោយជំងឺគ្រុនចាញ់។ នៅកំឡុងឆ្នាំ១៩៧០-៧៥ ជំងឺគ្រុនចាញ់មានតែ បន្តិចបន្តួចប៉ុណ្ណោះ ពីព្រោះអ្នកភូមិមានគ្នាតិច ហើយភាគច្រើនពួកគេមានការស៊ាំ ទៅនឹងជំងឺនេះ ម្យ៉ាងទៀតគេរកឃើញថ្នាំបុរាណដើម្បីដែលអាចព្យាបាលជំងឺគ្រុនចាញ់នេះប្រកបដោយប្រសិទ្ធភាព។ ១៩៧៥-១៩៧៩ ស្ថិតនៅក្នុងរបបប៉ុលពត ពួកគេបានជំលៀសប្រជាពលរដ្ឋដែលរស់នៅភ្នំពេញមករស់នៅតំបន់នេះ ពួកគាត់បានទទួលរងនូវជំងឺគ្រុនចាញ់យ៉ាង ខ្លាំងហើយភាគច្រើនស្លាប់បាត់បង់ជីវិតដោយសារជំងឺនេះ។ ឆ្នាំ១៩៨០-៩៣ជំងឺគ្រុនចាញ់ចាប់ផ្តើមថយចុះបន្តិចម្តងៗដោយ សារមានការផ្សព្វផ្សាយពីរដ្ឋាភិបាល និង អង្គការមួយចំនួនដែលបានផ្តល់មុង និង ថ្នាំជ្រលក់មុងជាដើម។ ឆ្នាំ១៩៩៣-០២ បច្ចុប្បន្នជំងឺគ្រុនចាញ់នៅត្រឹមតែ៥-៨%តែប៉ុណ្ណោះ។ អ្នកកើតជំងឺគ្រុនចាញ់ភាគច្រើនជាអ្នកក្រីក្រ ដែលគ្មានស្បៀងហូបគ្រប់គ្រាន់ និងទីជំរកមិនសមរម្យ ។

## បញ្ហាដែលប្រែប្រួលនៅភូមិកោះខ្សារ




រូបភាពទី ៥

32



ការប្រែប្រួលនៃសាលារៀនក្នុងភូមិ
ការបង្កើតសហគមន៍
វត្តអារាម
បញ្ហាទឹកជំនន់
ការប្រែប្រួលនៃជីក្រុមទាញ់ក្នុងភូមិ


រូបភាពទី ៥ ព 33

## ២-៤ ស្ថាប័ននិងដំណើរការ

*តារាងទី៤*

| ស្ថាប័ន | | វិជ្ជមាន | អព្យាក្រិត្យ | អវិជ្ជមាន |
|---|---|---|---|---|
| រដ្ឋាភិបាល | មេភូមិ | ✔ | | |
| | មេឃុំ | ✔ | | |
| | សាលារៀន | ✔ | | |
| | សាលាស្រុក | | ✔ | |
| | ពេទ្យសត្វស្រុក | ✔ | | |
| | ភ្នាក់ងារកសិកម្ម | | ✔ | |
| | យោធា | | ✔ | |
| | ប៉ូលីស | | ✔ | |
| | កាកបាទក្រហម | | ✔ | |
| | សាលាខេត្ត | | ✔ | |
| | ភ្នាក់ងារសុខាភិបាល | | ✔ | |
| | តុលាការ | | ✔ | |
| អ្នកធ្វើជំនួញ | ឈ្មួញទិញជ្រូក,គោ,ក្របី | ✔ | | |
| | អ្នកលក់ដូរក្នុងភូមិ | ✔ | | |
| | អ្នកទិញសរសរ | ✔ | | |
| | អ្នកទិញឬស្សី | ✔ | | |
| សង្គមស៊ីវិល | អង្គការ OCAA | ✔ | | |
| | គណៈកម្មការអភិវឌ្ឍន៍ភូមិ | ✔ | | |
| | គណៈកម្មការសហគមន៍ | ✔ | | |
| | ធនាគារស្រូវ | ✔ | | |
| | ពេទ្យសត្វភូមិ | ✔ | | |
| | គណៈកម្មការបុណ្យ | ✔ | | |
| | ឆ្មបបុរាណ | ✔ | | |
| | ពេទ្យឯកជន | ✔ | | |
| | ជាងផ្ទះ | | ✔ | |
| | ពេទ្យភូមិ ( ជនបង្គោល ) | | ✔ | |

យោងតាមលំហាត់វ៉ែនដ្យាក្រាម យើងឃើញថាមានមនុស្ស និង ស្ថាប័ន៣ក្រុមដែលមានទំនាក់ទំនង គឺរដ្ឋាភិបាល អ្នកធ្វើជំនួញ និងសង្គមស៊ីវិល។ អ្នកភូមិគិតថា ក្រុមទាំងនេះមានឥទ្ធិពលទៅលើការចិញ្ចឹមជីវិតរបស់ពួកគាត់។

*រដ្ឋាភិបាល*

មនុស្សនិងស្ថាប័នដែលស្ថិតនៅក្នុងក្រុមរដ្ឋាភិបាលជាច្រើន ដែលអ្នកភូមិគិតថាមានឥទ្ធិពលទៅលើការចិញ្ចឹមជីវិតរបស់គាត់ ហើយក្រុមទាំងនោះខ្លះមានឥទ្ធិពលវិជ្ជមាន និងខ្លះទៀតអ្នកចាត់ថាអព្យាក្រិត។ អព្យាក្រិតនេះមានន័យថាពួកគេមិនបានរំខានដល់ការចិញ្ចឹមជីវិតរបស់អ្នកភូមិ ហើយក៏មិនបានធ្វើអន្តរាគមន៍ណាមួយដែលជួយដល់អ្នកភូមិដែរ។ ក្នុងនោះអ្នកភូមិពេញចិត្តទៅលើអន្តរាគមន៍នានារបស់ មេភូមិ មេឃុំ សាលារៀន និង ពេទ្យសត្វស្រុក ព្រោះគាត់យល់ថាពេទ្យសត្វបានជួយដល់ពួកគាត់ពេលមានបញ្ហាសំខាន់ៗទាំងមនុស្ស និងសត្វចិញ្ចឹមក្នុងភូមិ ចំណែកសាលារៀន យ៉ាងហោចណាស់ក៏បាន ផ្តល់ចំណេះដឹងដល់កូនចៅគាត់ ក្នុងភូមិចេះអានចេះសរសេរបានខ្លះទោះបីមានត្រឹមថ្នាក់ទី៣ក៏ដោយ ចំណែកឯមេភូមិ មេឃុំជារដ្ឋអំណាចដែល តែងតែនៅជិតគាត់ ងាយស្រួលពឹងពាក់ពេលមានបញ្ហានានា។

ស្ថាបន័ផ្សេងៗទៀតដូចជា សាលាខេត្ត សាលាស្រុក តុលាការ ភ្នាក់ងារសុខាភិបាល កាកបាទក្រហម ភ្នាក់ងារកសិកម្ម សំខាន់សំរាប់ភូមិ និងប៉ុន្តែ ទៅនឹងមានទំនាក់ទំនងជាលក្ខណៈប្រយោលតាមរយៈភូមិ ឃុំ ដែលអ្នកភូមិ។

*អ្នកធ្វើជំនួញ :*

ភូមិកោះច្បារមានអ្នកលក់ដូរក្នុងភូមិចំនួន ៥ផ្ទះ អ្នកភូមិយល់ថាចំនុចនេះមានលក្ខណៈល្អប្រសើរ ពីព្រោះភូមិមានទីតាំងស្ថិតនៅឆ្ងាយពីទីប្រជុំជន។ ឈ្មួញទិញឬស្សី សរសរ ជ្រូក គោ ក្របី អ្នកភូមិគិតថា ជាចំនុចវិជ្ជមានមួយ ក្នុងការដោះស្រាយជីវភាពរបស់អ្នកភូមិ ។ ប្រាក់ចំណូលរបស់អ្នកភូមិគឺពឹងពាក់ទៅលើក្រុមឈ្មួញខាងលើនេះទាំងស្រុង ព្រោះពួកគាត់មានការលំបាកក្នុងការរកមធ្យោបាយដឹកជញ្ជូនផលិតផលមកលក់នៅទីផ្សារ។

*សង្គមស៊ីវិល :*

ក្រុមនេះមានអង្គការ OCAA ហើយអង្គការនេះបានបង្កើតឱ្យមាន គណៈកម្មការអភិវឌ្ឍន៍ភូមិ គណៈកម្មការសហគមន៍នេសាទ គណៈកម្មការជង្រុកស្រូវ ពេទ្យសត្វភូមិ ពេទ្យភូមិ (ជនបង្គោល) ឆ្មបបុរាណ ពួកគាត់ យល់ថាក្រុមនេះបានជួយបន្ធូរបន្ថយនូវការលំបាកមួយចំនួនធំរបស់អ្នកភូមិ។ នៅក្នុងភូមិក៏មានពេទ្យ

ឯកជនមួយដែរ ដែលអ្នកភូមិគិតថាពេទ្យនេះមានឥទ្ធិពលជាអព្យាក្រិតទៅលើការចិញ្ចឹមជីវិតរបស់គាត់ ព្រោះរាល់ការព្យាបាល និងថ្នាំអ្នកភូមិត្រូវចំណាយពេញថ្លៃ។

អង្គការ O CAA ការចូលរួមក្នុងការអភិវឌ្ឍន៏ភូមិរយៈពេល ប្រហែល ៥ឆ្នាំ កន្លងមកហើយមានគណៈកម្មការអភិវឌ្ឍន៏ភូមិចូលរួមសហការធ្វើការជាមួយប្រជាជន សហគមន៏នេសាទ ចូលរួមទប់ស្កាត់បទល្មើស នេសាទតាមព្រៃកនិងទន្លេមេគង្គ ធនាគារស្រូវជួយផ្តល់ស្រូវអោយអ្នកខ្វះពេលខ្វះខាត ពេទ្យសត្វភូមិជួយចាក់ថ្នាំការពារជំងឺ និង ព្យាបាលជំងឺសត្វ ពេទ្យភូមិ (ជនបង្គោល) ជួយអប់រំណែនាំពីបញ្ហាសុខភាពដល់ប្រជាជនក្នុងភូមិ និង កំពុងជំរុញការអនុវត្តន៏បន្តទៀតដើម្បីការរីកចំរើនក្នុងភូមិ ។

## ២.៥ យុទ្ធសាស្ត្រចិញ្ចឹមជីវិត

អ្នកភូមិមានយុទ្ធសាស្ត្រចិញ្ចឹមជីវិតផ្សេងៗគ្នាដោយយោងទៅតាមធនធាន មធ្យោបាយ និងជំនាញផ្ទាល់ខ្លួនដែលគេមាន។ ក្រុមអ្នកធូរធា និងអ្នកមធ្យម ច្រើនមានមុខរបរជាអ្នកធ្វើស្រែ និងចំការ ពួកនេះមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទិញសំភារៈកសិកម្ម មានសត្វពាហនៈដែលជាកំលាំងអូសទាញ និងមានដើមទន់សំរាប់ជួលកំលាំងពលកម្មក្នុងការងារបង្កបង្កើនផល។ ការនេសាទគេប្រើឧបករណ៏ជាលក្ខណៈគ្រួសារដូចជា លប មង សន្ទូច សំណាញ់ ចាន់។ ក្រៅពីនេះគ្រួសារមួយចំនួនមានមុខរបរផ្សេងៗទៀតដូចជា ម៉ាស៊ីនកិនស្រូវ វិទ្យុទាក់ទង បិតស្រា កាប់សរសរ កាប់ឬស្សី ឡើងត្នោត និងលក់ចាប់ហ៊ួយ។

ការធ្វើស្រែវស្សា និងស្រែបណ្តេញទឹកក៏ជាមុខរបរសំខាន់របស់ក្រុមគ្រួសារក្រីក្រដែរ ប៉ុន្តែក្រុមនេះមានដីស្រែតិចជាងក្រុមខាងលើហើយត្រូវការជួលមធ្យោបាយមួយចំនួនពីគេដូចជាកំលាំងអូសទាញ។ ក្នុងការងារនេសាទ គេប្រើឧបករណ៏ជាលក្ខណៈគ្រួសារដូចជា លប មង សន្ទូច សំណាញ់ ចាន់ ជាដើម គេអាចរកត្រីបានបន្តិចបន្តួចសំរាប់ផ្គត់ផ្គង់គ្រួសារ។ ក្រុមនេះមិនសូវមានមុខរបរផ្សេតៗទៀតដែលអាចរកចំណូលបានក្រៅពីការងារកសិដ្ឋានទេមានគ្រួសារមួយចំនួនដែលស៊ីឈ្នួលគេ ចាំងសរសរ បោចវល្លិ ផ្តៅ ដកស្ទូង ច្រូតកាត់ផងដែរ ។

ក្រុមគ្រួសារទីទ័លក្រពឹងផ្អែកជាសំខាន់ទៅលើការធ្វើស្រែវស្សាដោយជួលដី ឬប្រវ៉ាសដីពីគេ ពួកគាត់ទទួលផលបានតិចតួចព្រោះត្រូវចំណាយលើថ្លៃឈ្នួល។ ក្នុងការនេសាទពួកគាត់ប្រើប្រាស់ឧបករណ៏តូចៗជាលក្ខណៈគ្រួសារដូចជា មង លប សន្ទូច សំណាញ់ ចាន់ ដែលអាចចាប់ត្រីបានតិចតួច។ ក្រុមនេះភាគ ច្រើនជាអ្នកស៊ីឈ្នួលដកស្ទូង ច្រូតកាត់ កាប់ព្រៃ កាប់ឬស្សី ចាំងសរសរជាដើម។ ក្រៅពីនេះគេអាចទៅច្រូតស្បូវយកមកប្រក់ផ្ទះ និង ក្រងលក់ដែលបានកំរៃតែបន្តិចបន្តួច។

*ការចាត់ថ្នាក់និងវិភាគបញ្ហា*

ក្នុងការចិញ្ចឹមជីវិត អ្នកភូមិមានជួបបញ្ហាលំបាកមួយចំនួន។ ក្រុមសិក្សាបានសំរបសំរួលឱ្យអ្នកភូមិទាំងអស់ លើកឡើងនូវបញ្ហាដែលជួបប្រទះ ហើយធ្វើការចាត់ថ្នាក់រកបញ្ហាចំបងដើម្បីយកមកវិភាគរករឹសគល់នៃបញ្ហា និង រួមគ្នាផ្តល់ជាគំនិតរកគន្លឹះដោះស្រាយបញ្ហា។ ក្រុមបានប្រើវិធីសាស្ត្រប្រៀបធៀបបញ្ហាដើម្បីការចាត់ថ្នាក់រកបញ្ហាដែលចំបងរបស់ភូមិ។

១- ជំងឺសត្វ
២- ជំងឺមនុស្ស
៣-ខ្វះស្បៀង
៥- ខ្វះគ្រូបង្រៀន
៦-កង្វះកំលាំងអូសទាញ
៧-ខ្វះផ្លូវលំ

៤-ខ្វះវត្ត ៨-ខ្សត់ត្រី

*តារាងទី៥ ការប្រៀបធៀបបញ្ហា*

| ជំងឺសត្វ | ជំងឺមនុស្ស | ខ្វះស្បៀង | ខ្វះវត្ត | ខ្វះកំលាំងអូសទាញ | ខ្វះផ្លូវលំ | ខ្វះគ្រូបង្រៀន | ខ្សត់ត្រី |
|---|---|---|---|---|---|---|---|
| | ជំងឺមនុស្ស | ជំងឺសត្វ | ជំងឺសត្វ | ជំងឺសត្វ | ជំងឺសត្វ | ជំងឺសត្វ | ជំងឺសត្វ |
| | | ជំងឺមនុស្ស | ជំងឺមនុស្ស | ជំងឺមនុស្ស | ជំងឺមនុស្ស | ជំងឺមនុស្ស | ជំងឺមនុស្ស |
| | | | ខ្វះស្បៀង | ខ្វះស្បៀង | ខ្វះស្បៀង | ខ្វះកំលាំងអូសទាញ | ខ្វះស្បៀង |
| | | | | ខ្វះកំលាំងអូសទាញ | ខ្វះវត្ត | ខ្វះគ្រូបង្រៀន | ខ្វះវត្ត |
| | | | | | ខ្វះកំលាំងអូសទាញ | ខ្វះកំលាំងអូសទាញ | ខ្វះកំលាំងអូសទាញ |
| | | | | | | ខ្វះគ្រូបង្រៀន | ខ្វះផ្លូវលំ |
| | | | | | | | ខ្វះគ្រូបង្រៀន |
| ៦ | ៧ | ៤ | ២ | ៥ | ១ | ៣ | ០ |

តាមការប្រៀបធៀបបញ្ហាអ្នកភូមិបានយល់ព្រមលើបញ្ហាដែលជាចំបងពីរដែលកើតមានឡើងនៅក្នុងភូមិនេះមាន បញ្ហាទីមួយគឺជំងឺមនុស្ស ទីពីរជំងឺសត្វ។ ទាក់ទងទៅនឹងបញ្ហាសំខាន់ទាំងពីរនេះអង្គការ ជាំដែលកំពុងធ្វើការនៅក្នុងភូមិនេះបានកំពុងធ្វើអន្តរាគមន៍មួយចំនួនដើម្បីកាត់បន្ថយបញ្ហានេះ ដូចនេះក្រុមពិភាក្សាបានសំរេចលើកយកបញ្ហាទីបី ដែលមិនទាន់មានអន្តរាគមន៍យកមកធ្វើការវិភាគ។

**ការវិភាគបញ្ហាតាមរូបភាពដើមឈើ**

ក្នុងការវិភាគនេះយើងឃើញមានមូលហេតុសំខាន់មួយដែលធ្វើឱ្យអ្នកភូមិមានបញ្ហាគឺជំងឺមនុស្សនិងជំងឺសត្វ ។

***ផែនការសកម្មភាពវិភាគលើជំងឺសត្វ :***

អ្នកភូមិដែលចូលរួមពិភាក្សាបានសំរេចចិត្តធ្វើផែនការសកម្មភាពវិភាគលើជំងឺសត្វ និង ជំងឺមនុស្សដោយមានការផ្តល់យោបល់ឯកភាពទាំងបុរស និង ស្ត្រី។ ពួកគេមានការយល់ស្របគ្នាថាជាដំបូងត្រូវជ្រើស រើសអ្នកដឹកនាំសិនទើបអាចធ្វើការងារនេះបាន ហើយអ្នកដឹកនាំត្រូវធ្វើការទំនាក់ទំនងជាមួយរដ្ឋអំណាចមូល ដ្ឋានដើម្បីធ្វើវិភាគលើជំងឺសត្វ។

ជំហានបន្ទាប់ត្រូវទំនាក់ទំនងអង្គការស្ថាបន័ដែលពាក់ពន្ឋ័ក្នុងភូមិ អ្នកនៅក្នុងភូមិរបស់គាត់ និង ទំនាក់ទំនងសហការជាមួយគណៈកម្មការអភិវឌ្ឍន៏ភូមិ មេភូមិ និង មនុស្សសំខាន់ៗក្នុងភូមិដែលគាត់អាចពឹង ពាក់បាន ។



*តារាងទី ៦:* **តារាងផែនការសកម្មភាពឥណទានក្របី**

| ជំហាន | អ្នកផ្តួចផ្តើម | អ្នកចូលរួម | សំភារៈ | ពេលវេលា |
|---|---|---|---|---|
| ផ្សព្វផ្សាយពតិមានដល់អ្នកភូមិ | គណៈកម្មការអភិវឌ្ឍន៍ភូមិ ពេទ្យសត្វភូមិ | -អ្នកអត់គោ ក្របី<br>- គណៈកម្មការអភិវឌ្ឍន៍ | - ឯកសារ<br>- សំណើសុំ | ខែ ១២-៣/ឆ្នាំ |
| ទំនាក់ទំនង | -រៀបចំក្រុម<br>-គណៈកម្មការអភិវឌ្ឍន៍ភូមិ<br>-ពេទ្យសត្វភូមិ | -អ្នកអត់គោ ក្របី<br>-គណៈកម្មការអភិវឌ្ឍន៍ភូមិ<br>-ពេទ្យសត្វភូមិ | - ឯកសារ<br>- សំណើសុំ | ខែ ០២ / ឆ្នាំ |
| អនុវត្តន៍ | -ចូលរួមពិនិត្យពី គណៈកម្មការអភិវឌ្ឍន៍ភូមិ<br>- ពេទ្យសត្វភូមិ | -រួមគ្នាធ្វើលក្ខន្តិកៈសំរាប់អ្នកធ្វើឥណទានក្របី | -ច្បាប់ខ្ចី សង<br>- កិច្ចព្រមព្រៀង<br>-កិច្ចសន្យា | ខែ ០៣ / ឆ្នាំ |
| លទ្ធផល | - ត្រួតពិនិត្យពីពេទ្យសត្វភូមិ<br>- ក្រុមអ្នកអត់ក្របី<br>-គណៈកម្មការអភិវឌ្ឍន៍ភូមិ | - ទទួលបានក្របី<br>- ថែទាំ | -ទទួលបានក្របី<br>-អនុវត្តន៏<br>កិច្ចព្រមព្រៀង<br>កិច្ចសន្យា | ខែ ០៤ / ឆ្នាំ |

## ទំរង់និរន្តភាពនៃការចិញ្ចឹមជីវិតរបស់អ្នកភូមិកោះច្បារ



## ៣.ការសន្និដ្ឋាន

ផ្អែកលើពតិមានដែលក្រុមសិក្សាបានរៀនសូត្រពីអ្នកភូមិកោះច្បារ ក្រុមអាចធ្វើការសន្និដ្ឋានទៅលើរឿងរ៉ាវ និងបញ្ហា មួយចំនួនដែលកើតមានឡើងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ។

- ចំនួនប្រជាជនចេះតែកើនឡើងនាំឱ្យមានតំរូវការពង្រីកផ្ទៃដីកសិកម្មដែលធ្វើឱ្យបាត់បង់ធនធានធម្មជាតិ ការធ្វើនេសាទក្នុងភូមិ ពួកគាត់គោរពតាមលក្ខន្តិកៈសហគមន៍នេសាទដើម្បីនិរន្តភាពនៃធនធាន មច្ឆាជាតិ ។
- ការធ្វើស្រែវស្សាមានបញ្ហាលំបាក ដោយមានគ្រោះធម្មជាតិទឹកជំនន់ ដូចនេះពួកគាត់ត្រៀមពូជស្រូវ ស្រែបណ្តោញទឹក និងធ្វើស្រែវស្សានៅទីឆ្ងាយដែលមិនមានទឹកជំនន់លិចដល់ប្រជាជនភាគច្រើនក្នុង ភូមិពឹងផ្អែកលើស្រែ-ចំការ និង ការរុករកផល-អនុផលព្រៃឈើ ចាប់សត្វ នេសាទត្រី ។
- ប្រពន្ធ័ឥណទានប្រាក់ពួកគាត់ច្រើនរត់រកចងការពីអ្នកសំបូរ ជាប្រាក់ ឬ ស្រូវតាមការព្រមព្រៀង។ ដោយ មុខរបរធ្វើស្រែមានបញ្ហាធ្វើអោយអ្នកផ្តល់ប្រាក់រារែក មិនចង់អោយទៀតនៅពេលខ្វះខាត ។
- ប្រពន្ធ័ហេដ្ឋារចនាសម្ពន្ធ័ក្នុងភូមិនៅមានកំរិតទាបដែលធ្វើឱ្យអ្នកភូមិមានការលំបាកក្នុងមធ្យោបាយធ្វើ ដំណើរ និងដឹកជញ្ជូនផលផ្សេងៗ ដែលផលិតបាន (គ្មាន ផ្លូវ គ្មានស្ពាន) ។
- អ្នកក្រីក្រ និងអ្នកទីទ័លក្រកំពុងតែប្រឈមមុខក្នុងការលំបាក ខ្វះស្បៀង និងជំងឺផ្សេងៗ ។
- ប្រជាជនមានសាមគ្គីភាពល្អ ហើយលើការងារគ្រប់គ្រងភូមិមានមនុស្សសំខាន់ៗ ជាច្រើនដែលមានវ័យ ចំណាស់ៗ ដែលគិតគូរពីការអភិវឌ្ឍន៍ ដូចជា ចាស់ព្រឹទ្ធាចារ្យ គណៈកម្មការអភិវឌ្ឍន៍ គណៈកម្មការបុណ្យ គ្រូបង្រៀន និង មេភូមិដែលប្រជាជនមានជំនឿទុកចិត្ត។

**អនុសាសន៍**

យោងទៅលើការសន្និដ្ឋាន និងការរកឃើញនៅក្នុងភូមិ ក្រុមសិក្សាអាចចូលរួមផ្តល់ជា អនុសាសន៍មួយចំនួនដើម្បី ជាវិភាគទានក្នុងការអភិវឌ្ឍន៍ភូមិដូចខាងក្រោមៈ-

- គួរតែមានអន្តរាគមន៍ដែលទាក់ទងទៅនឹងវិស័យសុខាភិបាល
- គួរតែមានអន្តរាគមន៍ដែលទាក់ទងទៅនឹងវិស័យកសិកម្ម
- គួរតែមានអន្តរាគមន៍ដែលជួយក្នុងការដំណើរការបង្កើតសហគមន៍ព្រៃឈើ

- គួរជួយអន្តរាគមន៍ ស្មារតី សំភារៈដើម្បីទ្រទ្រង់ និង ពង្រឹងសហគមន៍នេសាទ ក៏ដូចជាសហគមន៍ផ្សេងៗដែរ ។
- គួរមានធនាគារ គោ ក្របី ដើម្បីជួយដល់ការអូសទាញ ជាមធ្យោបាយផលិតកម្ម របស់អ្នកភូមិ ។